ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# កម្មវិធីសិក្សាលម្អិត

មុខវិជ្ជា

# ប្រវត្តិវិទ្យា

សម្រាប់

## កម្រិតមធ្យមសិក្សាទុតិយភូមិ

២០១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥០៣ **អយក.**ប្រក

# ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ៣០២ អយក.ប្រក ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស
- តាមសំណើរបស់គណៈកម្មការនិងអនុគណៈកម្មការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល

## សម្រេច

**ប្រការ១ ..**

ប្រកាសដាក់ឱ្យប្រើជាផ្លូវការ "**កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិ**" ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២.-**

កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិនេះ មានមាតិកាសំខាន់ៗ ដូចខាងក្រោម៖

- សេចក្ដីផ្ដើម
- គោលបំណង
- គោលគំនិតសំខាន់ៗ
- របាយម៉ោងសិក្សា
- ការណែនាំអនុវត្ត
- ការវាយតម្លៃ
- តារាងកម្មវិធីសិក្សា

ខ្លឹមសារលម្អិតនៃកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជាកម្រិតមធ្យមសិក្សាបឋមភូមិជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៤.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ និងអ្នកពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៧រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែមីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួង អយក
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ៤ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ អគ.អរ

# បុព្វកថា

ការអប់រំជាវិស័យគន្លឹះមួយក្នុងការរួមចំណែកអភិវឌ្ឍធនធានមនុស្ស សំដៅជំរុញឱ្យសង្គមនិងសេដ្ឋកិច្ចរីកចម្រើន។ បច្ចុប្បន្ននេះ សង្គមនិងសេដ្ឋកិច្ចមានការអភិវឌ្ឍនិងការរីកចម្រើនដែលជាកម្លាំងចលករជំរុញឱ្យមានការកែលម្អការអប់រំ ដើម្បីអាចឆ្លើយតបទៅនឹងការវិវត្តថ្មីៗរបស់សង្គមនិងសេដ្ឋកិច្ច។ ប៉ុន្មានទសវត្សរ៍ចុងក្រោយនៃសតវត្សរ៍ទី២០និងដើមសតវត្សរ៍ទី២១នេះ សង្គមនិងសេដ្ឋកិច្ចឈានដល់បរិបទថ្មីដែលមិនធ្លាប់មានកន្លងមកដោយពិភពលោកកាន់តែបើកចំហ ការប្រកួតប្រជែងកាន់តែស្រួចស្រាល់ជាងមុន វិស័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកាន់តែទំនើបនិងប្រសើរឡើង។ កត្តាទាំងនេះនាំឱ្យប្រទេសឬជាតិសាសន៍នានាខិតខំពង្រឹងធនធានមនុស្សរបស់ខ្លួន ដើម្បីតាមឱ្យទាន់និងអាចឈរជើងប្រកបដោយឧត្តមភាពក្នុងបរិបទថ្មីនៃសង្គមនិងសេដ្ឋកិច្ចរបស់ពិភពលោក។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចថ្មី ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវការកែទម្រង់កម្មវិធីសិក្សាអប់រំចំណេះទូទៅដែលជាមូលដ្ឋានសម្រាប់ឱ្យអ្នកសិក្សាអាចបន្តការសិក្សានិងទទួលការបណ្តុះបណ្តាលផ្សេងៗទៀត សំដៅលើកកម្ពស់គុណភាពធនធានមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងកាយសម្បទា ដែលជាធាតុសំខាន់ក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នាតែប្រទាក់ក្រឡានិងគាំទ្រគ្នា។ កម្មវិធីសិក្សាលម្អិតកម្រិតមធ្យមសិក្សាបឋមភូមិនេះ បានបន្ថែមម៉ោងសិក្សាច្រើនជាងមុនទៅក្នុងកម្មវិធីសិក្សា។ ការកែទម្រង់កម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ សំដៅកសាងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំនៅកម្រិតបន្តដោយពង្រីកវិសាលភាពចំណេះដឹង បំណិនការអប់រំសីលធម៌ គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ព្រមទាំងផ្តល់នូវចំណេះដឹងមូលដ្ឋានផ្នែកបច្ចេកវិទ្យា បំណិនសតវត្សរ៍ទី២១ និងបំណិនសិក្សាពេញមួយជីវិត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ក្រសួង សង្ឃឹមយ៉ាងមុតមាំថា កម្មវិធីសិក្សាលម្អិតនេះនឹងបម្រើជាប្រយោជន៍ដ៏មានប្រសិទ្ធភាពក្នុងការអភិវឌ្ឍសៀវភៅសិក្សាគោល សម្ភារៈឧបទេស ឯកសារជំនួយនានាក្នុងការរៀននិងបង្រៀន និងឧបករណ៍ពិនិត្យតាមដាន វាយតម្លៃផ្សេងៗ។

ក្រសួង សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអនុគណៈកម្មការមុខវិជ្ជាឯកទេសទាំងអស់ លេខាធិការដ្ឋានកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានចូលរួមនិងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ព្រមទាំងដឹកនាំរៀបចំតាក់តែងកម្មវិធីសិក្សាលម្អិតនេះឱ្យបានសម្រេចជាផ្លែផ្កាឡើងនាពេលនេះ។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន**

# អារម្ភកថា

ប្រវត្តិសាស្ត្រជាផ្នែកមួយនៃអត្តសញ្ញាណ និងមោទនភាពនៃជាតិមួយ និងពិភពលោកដែលប្រជាជនត្រូវមានកាតព្វកិច្ចសិក្សា ស្វែងយល់ វិភាគ វាយតម្លៃ និងទាញយកបទពិសោធន៍ពីប្រវត្តិសាស្ត្រ ទោះបីជាប្រវត្តិសាស្ត្រមួយចំនួនមានលក្ខណៈរន្ធត់ និងប្រកបដោយភាពអាម៉ាស់ ដូចជាអំពើប្រល័យពូជសាសន៍ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យក៏ដោយ។ ការទទួលស្គាល់ការពិតនៃប្រវត្តិសាស្ត្រ ការចងចាំ ការចង់ដឹង និងចង់ស្វែងយល់ពីប្រវត្តិសាស្ត្រជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ និងការធានាចីរភាពអភិវឌ្ឍន៍ និងសន្តិភាព ជាពិសេសសម្រាប់ប្រទេសដែលទើបរួចផុតពីជម្លោះដូចជាប្រទេសកម្ពុជា។ ចំណេះ និងបំណិនប្រើប្រាស់ប្រវត្តិសាស្ត្រមានឥទ្ធិពលទៅលើឥរិយាបថផ្លូវចិត្ត និងការប្រព្រឹត្តរបស់ប្រជាជននាពេលបច្ចុប្បន្ន និងទៅអនាគត។ ការខ្វះខាតចំណេះដឹង និងបំណិនផ្នែកប្រវត្តិសាស្ត្រ ការយល់ខុស និងការបកស្រាយដោយគ្មានភស្តុតាងបុរាណវិទ្យា និងវិទ្យាសាស្ត្រ អាចបង្កជម្លោះក្នុងប្រទេសមួយ ឬរវាងប្រទេសនិងប្រទេសទាំងក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត។

បេសកកម្មនៃការសិក្សាប្រវត្តិសាស្ត្រ គឺសំដៅយល់ដឹងឱ្យច្បាស់អំពីខ្លួនឯង ពិចារណាអំពីផលប៉ះពាល់ និងផលវិបាកនៃប្រវត្តិសាស្ត្រ និងប្រើប្រវត្តិសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវការចូលរួម និងការទទួលខុសត្រូវក្នុងដំណើរការសង្គម។ ចំណេះដឹង និងបំណិនប្រវត្តិសាស្ត្រប្រកបដោយការត្រិះរិះពិចារណា និងការទទួលខុសត្រូវនឹងប្រែក្លាយអ្នកសិក្សាឱ្យទៅជាពលរដ្ឋសកម្ម ប្រកបដោយវិជ្ជាជីវៈ និងមនសិការ។ អតីតកាលជាប្រទីបបំភ្លឺបច្ចុប្បន្នកាល និងបង្ហាញផ្លូវទៅកាន់អនាគតកាល និងបង្កើតទំនាក់ទំនងរវាងបច្ចុប្បន្ន និងអនាគតដែលមិនអាចកាត់ផ្តាច់បាន។ ប្រសិនបើ អ្នកសិក្សាស្គាល់អតីតកាលកាន់តែច្បាស់ អ្នកសិក្សានឹងមានលទ្ធភាពរៀបចំអនាគតបានកាន់តែប្រសើរ។ ប្រជាជាតិមួយដែលគ្មានចំណេះដឹងអំពីអតីតកាល គឺមានន័យថា បានបាត់បង់អត្តសញ្ញាណ។ ពលរដ្ឋដែលស្គាល់ច្បាស់ពីអត្តសញ្ញាណជាតិ គឺស្រឡាញ់ជាតិ ខំបំពេញភារកិច្ចកសាង និងការពារជាតិ ដោយការទទួលខុសត្រូវ និងមនសិការ។

**អនុគណៈកម្មការមុខវិជ្ជាឯកទេសប្រវត្តិវិទ្យា**

# មាតិកា


ប្រកាស ........ i
បុព្វកថា ........ iii
អារម្ភកថា ........ iv
មាតិកា ........ v
១- សេចក្តីផ្តើម ........ ១
២- គោលបំណង ........ ១
៣- គោលគំនិតគន្លឹះសំខាន់ៗ ........ ៣
៤- របាយម៉ោងសិក្សា ........ ៧
៥- ការណែនាំអនុវត្ត ........ ៨
៦- ការវាយតម្លៃ ........ ១០
៧- តារាងកម្មវិធីសិក្សា ........ ១២
៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០ ........ ១២
៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១ ........ ២៤
៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២ ........ ៣៦
៨- សន្ទានុក្រម ........ ៥៣
៩- ឯកសារយោង ........ ៥៤
១០- បញ្ជីឈ្មោះគណៈកម្មការ ........ ៥៧

## ១- សេចក្តីផ្តើម

កម្មវិធីសិក្សាប្រវត្តិវិទ្យាសម្រាប់ប្រព័ន្ធអប់រំចំណេះទូទៅ និងបច្ចេកទេស ចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ត្រូវបានតាក់តែងឡើងតាមគោលវិធីរៀនបែបរិះរក លទ្ធផលរំពឹងទុក និងសិក្សាបញ្ញត្តិ។ ក្រោយពីបានសិក្សាប្រវត្តិវិទ្យា នៅគ្រប់ភូមិសិក្សាពីបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ អ្នកសិក្សាត្រូវទទួលបានគុណសម្បទាខ្ពស់បំផុត ដើម្បីក្លាយទៅជាពលរដ្ឋពេញលេញដែលចេះប្រើភស្តុតាងបុរាណវិទ្យា បាតុភូត និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាប្រយោជន៍ដល់ចីរភាពអភិវឌ្ឍ និងសន្តិភាពក្នុងពេលបច្ចុប្បន្ន និងអនាគត។

## ២- គោលបំណង

### ២.១- ការអប់រំប្រវត្តិវិទ្យា

ការអប់រំប្រវត្តិវិទ្យានឹងរួមចំណែកដល់ការប្រែក្លាយអ្នកសិក្សាឱ្យទៅជាពលរដ្ឋពេញលេញ ស្របតាមគោលបំណងរបស់ក្របខ័ណ្ឌកម្មវិធីសិក្សាជាតិ ដែលបានអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៥ ដោយបំពេញសក្តានុពលជាពលរដ្ឋដែលមាន ៖

- **ការទទួលខុសត្រូវខ្ពស់**ចំពោះរាល់ការសម្រេចចិត្ត និងការប្រព្រឹត្តរបស់ខ្លួន
- **ហេតុផល ដឹងខុសដឹងត្រូវ ចេះត្រិះរិះពិចារណា និងចេះប៉ាន់ប្រមាណ**អំពីឧបសគ្គ
- **គំនិតផ្តួចផ្តើម និងការច្នៃប្រឌិត** ក្នុងការរកដំណោះស្រាយបញ្ហា
- ***សុទិដ្ឋិនិយម ភាពអត់ធ្មត់* និងមិនទន់ជ្រាយ**ចំពោះឧបសគ្គ ឬការលំបាក
- ***ភាពជឿជាក់* និងឧត្តមភាព**ក្នុងការធ្វើការងារជាក្រុមជាប្រយោជន៍មនុស្សជាតិ
- **មានសីលធម៌ *សុជីវធម៌* និងគុណធម៌** ព្រមទាំង**គិតអំពីប្រយោជន៍មនុស្សជាតិ**។

### ២.២- គុណសម្បទាអ្នកសិក្សាប្រវត្តិវិទ្យា

ពលរដ្ឋគ្រប់ៗរូបសុទ្ធតែត្រូវការសេចក្តីសុខ និងវឌ្ឍនភាព ទាំងផ្លូវកាយ ផ្លូវចិត្ត និងចិត្តសង្គម ដោយពឹងអាស្រ័យជាធំលើវឌ្ឍិវិជ្ជា វឌ្ឍិបំណិន និងវឌ្ឍិចរិយា។ ដើម្បីស្ថាបនានិងរក្សាសេចក្តីសុខ និងវឌ្ឍនភាពនេះ អ្នកសិក្សាប្រវត្តិវិទ្យាគ្រប់ៗរូប ត្រូវអភិវឌ្ឍគុណសម្បទាមនុស្សខ្លាំងពូកែដែលមានទាំងវឌ្ឍិវិជ្ជា វឌ្ឍិបំណិន និងវឌ្ឍិចរិយា បូករួមទាំងគុណសម្បទាពលរដ្ឋសកល គុណសម្បទាសតវត្សរ៍ទី២១ និងគុណសម្បទាប្រវត្តិវិទ្យា។ ពិភពលោកក្នុងសតវត្សរ៍ទី២១ ត្រូវការពលរដ្ឋដែលមានគុណសម្បទាជាពលរដ្ឋពេញលេញ ដើម្បីរួមចំណែកដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាពឱ្យពិភពលោក។ កម្ពុជាដែលជាប្រទេសកំពុងអភិវឌ្ឍន៍ និងមានប្រាក់ចំណូលមធ្យមកម្រិតទាប កាន់តែត្រូវការពលរដ្ឋប្រភេទនេះ ដើម្បីប្រែក្លាយឱ្យទៅជាប្រទេសអភិវឌ្ឍន៍ដែលមានប្រាក់ចំណូលកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៥០ និងជាសន្តិប្រទេសជានិរន្តរ៍។ ដូច្នេះ សិស្សរៀននៅគ្រប់ភូមិសិក្សាត្រូវការឱ្យប្រព័ន្ធអប់រំបំពាក់គុណសម្បទាជាពលរដ្ឋពេញលេញចាប់ពីពេលនេះតទៅ តាមរយៈការពង្រីកកម្មវិធីសិក្សាគ្រប់មុខវិជ្ជា និងអភិវឌ្ឍគុណសម្បទាគ្រូពូកែ។ ក្រោយពីបានសិក្សាប្រវត្តិវិទ្យានៅសាលាចំណេះទូទៅ និងបច្ចេកទេស ចាប់ពីបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ អ្នកសិក្សាប្រវត្តិវិទ្យានឹងបានអភិវឌ្ឍគុណសម្បទាជាពលរដ្ឋពេញលេញ ចេះប្រើភស្តុតាង ទិន្នន័យ និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្របម្រើប្រយោជន៍មនុស្សជាតិ ៖

### ២.២.១- វិជ្ជាសម្បទា

- សន្និដ្ឋានរួមអំពីគោលបំណង និងចំណងពាក់ព័ន្ធនៃប្រវត្តិសាស្ត្រ សម្រាប់ផ្សារភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃរបស់មនុស្ស និងធម្មជាតិ ក្នុងបច្ចុប្បន្នកាល និងអនាគតកាល
- ពន្យល់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ទាំងនៅមើលឃើញ និងបាត់បង់ ដូចជា មនុស្ស ទីកន្លែង ដោយប្រើភស្តុតាងបុរាណវិទ្យា និងវិទ្យាសាស្ត្រ
- ចងក្រងប្រវត្តិសាស្ត្រនៃបម្រែបម្រួលសង្គមមនុស្ស ទីកន្លែង មរតកវប្បធម៌ និងធម្មជាតិក្នុងអតីតកាលដែលបន្តនិរន្តរភាពមកដល់បច្ចុប្បន្ន និងទៅអនាគត

### ២.២.២- បំណិនសម្បទា

- បង្កើតទម្រង់ និងមធ្យោបាយនៃការប្រាស្រ័យទាក់ទងល្អ និងវិជ្ជមាន ជាមួយមនុស្ស ធម្មជាតិ និងមរតកប្រវត្តិសាស្ត្រ
- វិភាគចលករនៃបម្រែបម្រួលប្រជាសាស្ត្រ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលបានបង្កើតប្រវត្តិសាស្ត្រក្នុងប្រទេស តំបន់ និងពិភពលោក
- បង្កើតជម្រើស និងមធ្យោបាយនៃដំណោះស្រាយបញ្ហាវប្បធម៌ សង្គម សេដ្ឋកិច្ច និងនយោបាយប្រកបដោយការទទួលខុសត្រូវ ក្រមសីលធម៌ និងច្នៃប្រឌិត

### ២.២.៣- ចរិយាសម្បទា

- ឱ្យតម្លៃចំពោះភាពរួម ភាពដោយឡែក និងនានាភាព នៃវប្បធម៌ សាសនា ទំនៀមទម្លាប់ ជំនឿ និងប្រពៃណី ក្នុងប្រវត្តិសាស្ត្រ ទាំងក្នុងប្រទេស តំបន់ និងពិភពលោក
- ផ្សារភ្ជាប់គុណតម្លៃនៃមរតកប្រវត្តិសាស្ត្រទៅនឹងបច្ចុប្បន្នកាល និងអនាគតកាល
- បណ្តុះសុជីវធម៌ សីលធម៌ គុណធម៌ សម្មាទិដ្ឋិ និងការច្នៃប្រឌិតដោយរៀនសូត្រពីមរតកប្រវត្តិសាស្ត្រ។

## ២.៣- មធ្យមសិក្សាទុតិយភូមិថ្នាក់ទី១០ ដល់ទី១២

ដើម្បីធានាសម្រេចគោលដៅអប់រំ ក្នុងការបំពាក់គុណសម្បទាជាពលរដ្ឋពេញលេញ កម្មវិធីសិក្សាលម្អិតសម្រាប់មធ្យមសិក្សាបឋមភូមិ បំពាក់គុណសម្បទាប្រវត្តិវិទ្យា គុណសម្បទាសតវត្សរ៍ទី២១ និងគុណសម្បទាពលរដ្ឋសកល។ ក្នុងកម្រិតអប់រំមធ្យមសិក្សាបឋមភូមិចាប់ពីថ្នាក់ទី៧ដល់ទី៩ សិស្សចូលក្នុងវ័យប្រហែលពី១៣ដល់១៥ឆ្នាំដែលមានសញ្ញាណបញ្ញាក្នុងការស្វែងយល់អំពីពិភពខាងក្រៅ ចង់ឃើញពិភពលោកដែលល្អប្រសើរ មានបេះដូងចង់ជួយអ្នកដទៃ ចង់ក្លាយជាមនុស្សខ្លាំងពូកែ និងត្រៀមខ្លួនចូលប្រឡូកក្នុងដំណើរការសង្គមដែលមានការប្រែប្រួលឆាប់រហ័ស និងមានចំណងប្រទាក់ក្រឡាគ្រប់ស្រទាប់។ លើសពីនេះទៀត សិស្សក្នុងវ័យនេះត្រូវការគុណសម្បទាជាមនុស្សពេញលេញ រួមមានវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា សម្រាប់យកទៅបន្តការសិក្សា បម្រើមនុស្សជាតិ និងរស់ក្នុងសង្គមដ៏ស្មុគស្មាញ និងនវកម្មសេដ្ឋកិច្ច។ ដូច្នេះ ការសិក្សាប្រវត្តិវិទ្យាត្រូវបំពាក់គុណសម្បទាខាងក្រោម ៖

### វិជ្ជាសម្បទា

- ប្រើភស្តុតាង ទិន្នន័យ និងព្រឹត្តការណ៍ប្រវត្តិសាស្ត្រ សម្រាប់បន្តការសិក្សា បម្រើការងារ និងជីវភាពរស់នៅប្រចាំថ្ងៃ
- ភ្ជាប់អន្តរទំនាក់ទំនងនៃអរិយធម៌ វប្បធម៌ សង្គម សេដ្ឋកិច្ច និងនយោបាយ ក្នុងប្រវត្តិសាស្ត្រគ្រប់សម័យកាលក្នុងពិភពលោក សម្រាប់ជាប្រយោជន៍ ដល់ជីវភាពប្រចាំថ្ងៃរបស់មនុស្សជាតិក្នុងបច្ចុប្បន្នកាលនិងអនាគតកាល

**បំណិនសម្បទា**

- ប្រាស្រ័យទាក់ទងល្អ វិជ្ជមាន និងប្រកបដោយការច្នៃប្រឌិត ជាមួយធម្មជាតិ មនុស្ស និងមរតកប្រវត្តិសាស្ត្រទាំងក្នុងប្រទេស តំបន់ និងពិភពលោក
- បង្កើតជម្រើសនៃដំណោះស្រាយបញ្ហាផ្នែកវប្បធម៌ សង្គម សេដ្ឋកិច្ច និងនយោបាយប្រកបដោយការច្នៃប្រឌិតក្នុងផ្នត់គំនិតរក្សាប្រយោជន៍រួមសម្រាប់មនុស្សជាតិ

**ចរិយាសម្បទា**

- ដាំបណ្ដុះការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមានក្នុងការថែរក្សា និងអភិវឌ្ឍមរតកប្រវត្តិសាស្ត្រ ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ
- ប្រតិបត្តិគោលការណ៍នៃសុជីវធម៌ សីលធម៌ និងគុណធម៌ ជាប្រយោជន៍ដល់មនុស្សជាតិ
- វិនិច្ឆ័យពីតម្លៃនៃភាពរួម និងភាពដោយឡែកអរិយធម៌ វប្បធម៌ សង្គម នយោបាយ និងសេដ្ឋកិច្ចក្នុងប្រវត្តិសាស្ត្រ តាមប្រទេស តំបន់ និងពិភពលោក។

## ៣- គោលគំនិតសំខាន់ៗ

### ៣.១- គោលវិធីរៀននិងបង្រៀន

គោលវិធីរៀននិងបង្រៀនមានច្រើនបែបច្រើនយ៉ាងកំពុងអនុវត្តតាមសាលារៀន ដូចជា គោលវិធីរៀនបែបរិះរក គោលវិធីសិស្សមជ្ឈមណ្ឌល គោលវិធីរៀនបែបសហការ គោលវិធីរៀនបែបគម្រោង និងគោលវិធីរៀនតាមបញ្ហា។ ការសរសេរកម្មវិធីសិក្សាប្រវត្តិវិទ្យា ប្រើគោលវិធីរៀនបែបរិះរក។ គោលវិធីនេះបង្កបរិយាកាសរៀននិងបង្រៀន ដោយឱ្យអ្នកសិក្សា និងគ្រូបង្រៀនចេះប្រើការឆ្ងល់ ការសួរ ការស្រាវជ្រាវ និងឆ្លើយតបទៅនឹងតម្រូវការនិងធម្មជាតិរបស់កុមារ និងយុវជនក្នុងសតវត្សរ៍ទី២១។ គោលវិធីនេះជួយអ្នកសិក្សាឱ្យមានបុច្ចនបំណិន និងសង្កប្បបំណិន ដោយចេះគិត វិភាគ និងសន្និដ្ឋាន និងប្រើភស្តុតាង បានពីការស្រាវជ្រាវ និងប្រែក្លាយពីការឆ្ងល់ឱ្យទៅជាពុទ្ធិថ្មី។

### ៣.២- លទ្ធផលសិក្សារំពឹងទុក

សាកល្បងគិតបន្តិចមើល! មុនចូលរៀនមួយម៉ោង ឬតិចជាងមួយម៉ោងជាមួយគ្រូបង្រៀនម្នាក់ លើមុខវិជ្ជាប្រវត្តិវិទ្យា តើអ្នកត្រូវទទួលបានវិជ្ជាអ្វី បំណិនអ្វី និងចរិយាអ្វីពីមេរៀននេះ សម្រាប់ជាប្រយោជន៍ដល់ការសិក្សាបន្ត ការរស់នៅប្រចាំថ្ងៃ និងជួយធ្វើឱ្យប្រសើរដល់សង្គម?

ឧទាហរណ៍ រៀនមេរៀនអំពីមនុស្សសំខាន់ៗ ក្នុងប្រវត្តិសាស្ត្រខ្មែរនៅសតវត្សរ៍ទី៩ តើអ្នកត្រូវទទួលបានវិជ្ជាអ្វី បំណិនអ្វី និងចរិយាអ្វីពីមេរៀននេះ ដើម្បីយកទៅប្រើជាគោលប្រយោជន៍ ដល់ការសិក្សាបន្ត ដល់ជីវភាពប្រចាំថ្ងៃ និងដើម្បីជួយដល់អ្នកដទៃ គ្រួសារ សាលារៀន សហគមន៍ ប្រទេស តំបន់ និងពិភពលោក ក្នុងបច្ចុប្បន្នកាល និងអនាគតកាល? ខ្ញុំត្រូវការរៀនអំពីគោលការណ៍ដឹកនាំប្រទេសរបស់ព្រះរាជាសម័យកាលទាំងនោះ អំពីចរិតលក្ខណៈជាអ្នកដឹកនាំដោយឈរលើគោលការណ៍ទសពិធរាជធម៌ និងចង់វិភាគអំពីកត្តានាំឱ្យចក្រភពអង្គររុងរឿង ហើយខ្ញុំក៏ត្រូវការភ្ជាប់ទម្រង់នៃការដឹកនាំរបស់ព្រះរាជាសម័យកាលមុនៗទៅនឹងទម្រង់នៃការដឹកនាំប្រទេសបច្ចុប្បន្ន និងអនាគត។

លទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាសំដៅដល់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដែលត្រូវប្រើក្នុងការសិក្សាបន្ត ជីវភាពប្រចាំថ្ងៃ និងការងារជាប្រយោជន៍ដល់មនុស្សជាតិ។

## ៣.៣- សិក្សាបញ្ញត្តិ

កម្មវិធីសិក្សាប្រវត្តិវិទ្យាផ្ដោតលើគោលសំខាន់មួយទៀតគឺសិក្សាបញ្ញត្តិ។ សិក្សាបញ្ញត្តិនាំសិស្ស និងគ្រូឱ្យគិត និងស្វែងយល់តាមរយៈការឆ្លល់ទៅលើខ្លឹមសារគោលនៃមេរៀន និងប្រែក្លាយការឆ្ងល់ឱ្យទៅជាពុទ្ធិថ្មីពីបញ្ញត្តិនីមួយៗក្នុងមេរៀន។ គ្រប់មេរៀននៃមុខវិជ្ជាប្រវត្តិវិទ្យានៅគ្រប់កម្រិត ផ្ដល់លំនាំឱ្យសិស្សស្វែងយល់ពីបញ្ញត្តិជាមុន ដើម្បីឈានទៅទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពីមេរៀន តាមរយៈសកម្មភាពស្រាវជ្រាវ រៀន និងបង្រៀន។

## ៣.៤- គុណតម្លៃនៃប្រវត្តិវិទ្យា

ប្រវត្តិសាស្ត្រជាអត្តសញ្ញាណ និងមោទនភាពនៃប្រជាជាតិមួយ និងពិភពលោកទាំងមូល។ ដូច្នេះ ជាប្រជាជននៃជាតិមួយ និងរបស់ពិភពលោក ត្រូវមានកាតព្វកិច្ចសិក្សា វិភាគ វាយតម្លៃ ទាញយកបទពិសោធន៍ និងប្រើប្រាស់

ភស្តុតាង និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាប្រយោជន៍ដល់មនុស្សជាតិ ព្រមទាំងចេះវាយតម្លៃបច្ចុប្បន្នកាល និងធ្វើចំណោលអំពីអនាគតកាល។ ដូចគ្នានេះដែរ ការសិក្សាប្រវត្តិវិទ្យា គឺសំដៅអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដើម្បីរកមធ្យោបាយ និងជម្រើសនៃដំណោះស្រាយបញ្ហាសង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ ព្រមទាំងរួមចំណែកដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាពសម្រាប់មនុស្សជាតិ។

ក្រោយពីទទួលបានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ពីការសិក្សាប្រវត្តិសាស្ត្រ អ្នកសិក្សានឹងផ្លាស់ប្ដូរការគិត ការសម្រេចចិត្ត និងការប្រព្រឹត្ត ព្រមទាំងចេះវាយតម្លៃអំពីខ្លួនឯង ពិចារណាអំពីផលប៉ះពាល់ និងផលវិបាកនៃប្រវត្តិសាស្ត្រ ព្រមទាំងប្រកាន់ខ្ជាប់ និងប្រតិបត្តិគោលការណ៍សុជីវធម៌ សីលធម៌ និងគុណធម៌ជាប្រយោជន៍ដល់មនុស្សជាតិ។

## ៣.៥- ទស្សនវិជ្ជានៃប្រវត្តិវិទ្យា

ការសិក្សាប្រវត្តិវិទ្យាសំដៅបណ្ដុះការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមាន និងប្រកបដោយការច្នៃប្រឌិតរបស់អ្នកសិក្សាដោយឱ្យអ្នកសិក្សាចេះកោតសរសើរចំពោះមរតកប្រវត្តិសាស្ត្រ និងផ្សារភ្ជាប់ប្រវត្តិសាស្ត្រទៅនឹងបច្ចុប្បន្នកាល និងអនាគតកាល ព្រមទាំងប្រើប្រាស់បទពិសោធន៍អតីតកាល ដើម្បីជាមេរៀនជីវិត ក្នុងការបង្កើតជម្រើសនៃដំណោះស្រាយបញ្ហា និងបញ្ចៀសបញ្ហានៃកំហុសប្រវត្តិសាស្ត្រដដែលៗ។

## ៣.៦- ប្រវត្តិវិទ្យានិងគុណសម្បទាពលរដ្ឋសកល

ក្នុងយុគសម័យបច្ចេកវិទ្យាព័ត៌មាន និម្មិតកម្មសង្គម និងនវកម្មសេដ្ឋកិច្ច មនុស្សត្រូវមានអន្តរទំនាក់ទំនងជាមួយជាតិសាសន៍ នយោបាយ វប្បធម៌ សង្គម និងសេដ្ឋកិច្ចនៃប្រទេសដទៃនៅទូទាំងពិភពលោក។ ការរីកចម្រើនដ៏ឆាប់រហ័សនៃបច្ចេកវិទ្យាកំពុងជំរុញ និងពង្រីកសក្ដានុពលដល់សកលភាវូបនីយកម្ម ដូច្នេះពលរដ្ឋគ្រប់ជាតិសាសន៍ ត្រូវរួមរស់ជាមួយគ្នា និងឱ្យតម្លៃចំពោះភាពរួមគ្នា ភាពដោយឡែក និងនានាភាពនៃវប្បធម៌ នយោបាយ សាសនា ទំនៀមទម្លាប់ ប្រពៃណី និងជំនឿផ្សេងៗគ្នា។ ការស្រាវជ្រាវជាច្រើនបានរកឃើញថា ពលរដ្ឋដែលមានគុណសម្បទាពលរដ្ឋសកល អាចរស់នៅ និងធ្វើការក្នុងគ្រប់បរិបទនៃប្រពៃណី ទំនៀមទម្លាប់ និងជំនឿ និងចូលរួមដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាពពិភពលោក។ ដូច្នេះ ដើម្បីធានាឱ្យមនុស្សជំនាន់ក្រោយរស់ក្នុងសេចក្ដីសុខ វឌ្ឍនភាព និងសន្តិភាពជាមួយពិភពលោក កម្មវិធីសិក្សាមុខវិជ្ជាប្រវត្តិវិទ្យាក្នុងប្រព័ន្ធអប់រំ ចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ត្រូវបញ្ចូលគុណសម្បទាពលរដ្ឋសកល។ ការបញ្ចូលគុណសម្បទាពលរដ្ឋសកលផ្ដល់ប្រយោជន៍ដល់អ្នកសិក្សា និងសង្គមតាមមធ្យោបាយធំៗបី ៖បង្ហាញផែនទីអំពីផលនៃអតីតកាលបន្សល់ទុកឱ្យបច្ចុប្បន្ន និងបន្តរក្សាឱ្យអនាគត

- បង្ហាញផែនទីអំពីផលនៃអតីតកាលបន្សល់ទុកឱ្យបច្ចុប្បន្ន និងបន្តរក្សាឱ្យអនាគត នូវទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ប្រទេស តំបន់ និងពិភពលោក

- វិភាគបាតុភូត ចលករ និងព្រឹត្តិការណ៍សង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ ដោយប្រើភស្តុតាងបុរាណវិទ្យា និងវិទ្យាសាស្ត្រ និងវិធីសាស្ត្រប្រវត្តិសាស្ត្រ កម្រិតមូលដ្ឋាន ប្រទេស តំបន់ និងពិភពលោក
- បង្កើតទម្រង់ និងជម្រើសនៃដំណោះស្រាយបញ្ហាសង្គម វប្បធម៌ នយោបាយ និងសេដ្ឋកិច្ច ប្រកបដោយការទទួលខុសត្រូវ និងការច្នៃប្រឌិត ដោយប្រើវិធីសាស្ត្រប្រវត្តិសាស្ត្រ និងប្រកាន់ខ្ជាប់គោលការណ៍សន្តិភាពសម្រាប់ជាប្រយោជន៍ដល់មូលដ្ឋាន ប្រទេស តំបន់ និងពិភពលោក។

### ៣.៧- ប្រវត្តិវិទ្យានិងគុណសម្បទាសតវត្សរ៍ទី២១

ការអភិវឌ្ឍបច្ចេកវិទ្យា និម្មិតកម្មសង្គម និងនវកម្មសេដ្ឋកិច្ចកំពុងបង្កើតឱ្យមានបដិវត្តន៍ថ្មីមួយ ហៅថា បដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ បដិវត្តន៍ថ្មីនេះបាននាំមកនូវសកលភាវូបនីយកម្មដ៏ប្រទាក់ក្រឡា និងបម្រែបម្រួលប្រជាសាស្ត្រ សង្គម វប្បធម៌ នយោបាយ សេដ្ឋកិច្ច និងទម្រង់នៃការរស់នៅរបស់មនុស្ស ដែលពឹងអាស្រ័យជាធំលើអ៊ីនធឺណែត ឌីជីថល និងឧបករណ៍បច្ចេកវិទ្យាព័ត៌មាន។ ការស្រាវជ្រាវជាច្រើនបានរកឃើញថា ការរីកចម្រើនផ្នែកបច្ចេកវិទ្យានៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ មានល្បឿនពហុគុណលឿនជាងបដិវត្តន៍ឧស្សាហកម្មជំនាន់មុនៗ។ ដើម្បីធានាឱ្យមនុស្សជំនាន់ក្រោយរស់នៅល្អប្រសើរ មានសេចក្តីសុខ និងទាន់បច្ចេកវិទ្យានៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ កម្មវិធីសិក្សាប្រវត្តិវិទ្យាត្រូវបញ្ចូលគុណសម្បទាសតវត្សរ៍ទី២១ បន្ថែមលើគុណសម្បទាប្រវត្តិវិទ្យា និងពលរដ្ឋសកល។

**គុណសម្បទាសតវត្សរ៍ទី២១**



## ៣.៨- ប្លង់គោលនៃមេរៀន

### ថ្នាក់ទី១០

**ជំពូកទី១ ប្រវត្តិសាស្រ្តកម្ពុជាក្នុងបរិបទតំបន់ និងពិភពលោក**

មេរៀនទី១៖ ប្រវត្តិវិទ្យា និងលក្ខណៈវិនិច្ឆ័យ

មេរៀនទី២៖ បុរេប្រវត្តិសាស្រ្តកម្ពុជា និងអន្តរកម្ម

មេរៀនទី៣៖ ហ្វូណន និងមហាអំណាចក្នុងតំបន់

មេរៀនទី៤៖ ចេនឡា និងដំណើរឆ្ពោះទៅរកឧត្តមភាព

មេរៀនទី៥៖ ចក្រភពអង្គរ និងមហាអំណាចក្នុងតំបន់

**ជំពូកទី២ អាណានិគម និងបម្រែបម្រួលសង្គមអាស៊ីអាគ្នេយ៍ (សតវត្សរ៍ទី១៩-២០)**

មេរៀនទី១៖ អាណានិគមរបស់អឺរ៉ុបនៅអាស៊ីអាគ្នេយ៍

មេរៀនទី២៖ ជ្រោយម៉ាឡាយូ និងអាណានិគមរបស់អង់គ្លេស

មេរៀនទី៣៖ វៀតណាម និងអាណានិគមរបស់បារាំង

មេរៀនទី៤៖ ឥណ្ឌូណេស៊ី និងអាណានិគមរបស់ហូឡង់

**ជំពូកទី៣ សង្គ្រាមលោកលើកទី១ និងវិបត្តិនៅអឺរ៉ុប(១៩១៤-១៩៣៩)**

មេរៀនទី១៖ មហាអំណាចមុនសង្គ្រាមលោកលើកទី១ និងវិបត្តិពិភពលោក

មេរៀនទី២៖ សង្គ្រាមលោកលើកទី១ និងផលវិបាក

មេរៀនទី៣៖ សន្ធិសញ្ញាទីក្រុងវែរសៃ និងអត្ថន័យចំពោះអាល្លឺម៉ង់

មេរៀនទី៤៖ សង្គមប្រជាជាតិ និងបរាជ័យ

### ថ្នាក់ទី១១

**ជំពូកទី១ ប្រវត្តិសាស្រ្តកម្ពុជាក្នុងបរិបទតំបន់ និងពិភពលោក**

មេរៀនទី១៖ ចតុមុខ និងរាជធានីថ្មី

មេរៀនទី២៖ លង្វែក និងអំណាចសៀម

មេរៀនទី៣៖ ឧដុង្គ និងការប្រជែងអំណាចរវាងសៀម និងយួន

មេរៀនទី៤៖ កម្ពុជា និងអាណាព្យាបាលបារាំង

**ជំពូកទី២ អាស៊ីអាគ្នេយ៍ និងឯករាជ្យ (សតវត្សរ៍ទី២០)**

មេរៀនទី១៖ អាស៊ីអាគ្នេយ៍ និងការបញ្ចប់អាណានិគមរបស់អឺរ៉ុប

មេរៀនទី២៖ ជ្រោយម៉ាឡាយូ និងឯករាជ្យ

មេរៀនទី៣៖ វៀតណាម និងឯករាជ្យ

មេរៀនទី៤៖ ឥណ្ឌូណេស៊ី និងឯករាជ្យ

**ជំពូកទី៣ សង្គ្រាមលោកលើកទី២ និងការបែងចែកពិភពលោក(១៩៣៩-១៩៤៥)**

មេរៀនទី១៖ ពិភពលោក និងវិបត្តិនៅចន្លោះសង្គ្រាមលោកទាំងពីរ

មេរៀនទី២៖ សង្គ្រាមលោកលើកទី២ និងផលវិបាក

មេរៀនទី៣៖ អង្គការសហប្រជាជាតិ និងទិសដៅសន្តិភាព

មេរៀនទី៤៖ មជ្ឈិមបូព៌ា និងបញ្ហាជាតិសាសន៍

**ថ្នាក់ទី១២**

**ជំពូកទី១ ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទតំបន់ និងពិភពលោក**

មេរៀនទី១៖ សង្គមរាស្ត្រនិយម និងសង្គ្រាមត្រជាក់

មេរៀនទី២៖ សាធារណរដ្ឋខ្មែរ និងឥទ្ធិពលបរទេស

មេរៀនទី៣៖ សាធារណរដ្ឋប្រជាមានិតកម្ពុជាជាមួយមិត្ត និងសត្រូវ

មេរៀនទី៤៖ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា

មេរៀនទី៥៖ ព្រះរាជាណាចក្រកម្ពុជាទីពីរ និងស្ថិរភាព

**ជំពូកទី២ អាស៊ាន (១៩៦៧-បច្ចុប្បន្ន)**

មេរៀនទី១៖ អាស៊ាន និងបញ្ហាប្រឈម

មេរៀនទី២៖ អាស៊ាន និងសកលភាវូបនីយកម្ម

**ជំពូកទី៣ សង្គ្រាមត្រជាក់ និងសាកលភាវូបនីយកម្ម(១៩៤៧-បច្ចុប្បន្ន)**

មេរៀនទី១៖ មហាអំណាចមនោគមវិជ្ជាសេរី និងណាតូ

មេរៀនទី២៖ មហាអំណាចមនោគមវិជ្ជាកុម្មុយនីស្ត និងអង្គការនានា

មេរៀនទី៣៖ សង្គ្រាមត្រជាក់ និងផលប៉ះពាល់

មេរៀនទី៤៖ បញ្ហាពិភពលោក និងសកលភាវូបនីយកម្មក្រោយសង្គ្រាមត្រជាត់

មេរៀនទី៥៖ ពិភពលោក និងបដិវត្តន៍ឧស្សាហកម្មទី៣

## ៤- របាយម៉ោងសិក្សា

| មុខវិជ្ជា ប្រវត្តិវិទ្យា | ជំពូក១ ប្រវត្តិសាស្ត្រកម្ពុជា | ជំពូក២ ប្រវត្តិសាស្ត្រតំបន់ | ជំពូក៣ ប្រវត្តិសាស្ត្រពិភពលោក | ម៉ោងសរុប |
|---|---|---|---|---|
| ថ្នាក់ទី១០ | វិ. សង្គម ៧០ម៉<br>វិទ្យាសាស្ត្រ ៣៥ម៉ | វិ. សង្គម ៤០ ម៉<br>វិទ្យាសាស្ត្រ ២០ ម៉ | វិ. សង្គម ៣០ម៉<br>វិទ្យាសាស្ត្រ ១៥ ម៉ | វិ. សង្គម ១៤០ម៉<br>វិទ្យាសាស្ត្រ ៧០ម៉ |
| ថ្នាក់ទី១១ | វិ. សង្គម ៧០ម៉<br>វិទ្យាសាស្ត្រ ៣៥ម៉ | វិ. សង្គម ៤០ ម៉<br>វិទ្យាសាស្ត្រ ២០ ម៉ | វិ. សង្គម ៣០ម៉<br>វិទ្យាសាស្ត្រ ១៥ ម៉ | វិ. សង្គម ១៤០ម៉<br>វិទ្យាសាស្ត្រ ៧០ម៉ |
| ថ្នាក់ទី១២ | វិ. សង្គម ៧០ម៉<br>វិទ្យាសាស្ត្រ ៣៥ម៉ | វិ. សង្គម ៤០ ម៉<br>វិទ្យាសាស្ត្រ ២០ ម៉ | វិ. សង្គម ៣០ម៉<br>វិទ្យាសាស្ត្រ ១៥ ម៉ | វិ. សង្គម ១៤០ម៉<br>វិទ្យាសាស្ត្រ ៧០ម៉ |

**កំណត់សម្គាល់៖**

១ឆ្នាំសិក្សាមាន៣៥សប្តាហ៍ x ៤ម៉ = ១៤០ ម៉ោង(បណ្តុំវិទ្យាសាស្ត្រសង្គម)

១ឆ្នាំសិក្សាមាន៣៥សប្តាហ៍ x ២ម៉ = ៧០ ម៉ោង(បណ្តុំវិទ្យាសាស្ត្រ)

១សប្តាហ៍ = ៤ ម៉ោងសិក្សា ១ម៉ោងសិក្សា = ៥០ នាទី

## ៥- ការណែនាំអនុវត្ត

### ៥.១- វិធីសាស្ត្របង្រៀន

ការសរសេរកម្មវិធីសិក្សាប្រវត្តិវិទ្យានេះបានប្រើគោលវិធីរៀនបែបរិះរក លទ្ធផលរំពឹងទុក និងសិក្សាបញ្ញត្តិ។ គោលវិធីទាំងនេះផ្តល់មធ្យោបាយឱ្យអ្នកសិក្សាគិតអំពីអតីតកាល និងភ្ជាប់សារប្រយោជន៍នៃអតីតកាលជាមួយនឹងជីវភាពបច្ចុប្បន្ន និងអនាគត។ ក្នុងន័យនេះ អ្នកសិក្សាប្រវត្តិវិទ្យាប្រើការឆ្ងល់ដើម្បីបង្កើតពុទ្ធិថ្មី តាមរយៈការរុករក ឬស្រាវជ្រាវ និងយករបកគំហើញពីការឆ្ងល់ទៅពន្យល់ និងវិភាគបាតុភូត និងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ (ដែលមានប្រភពត្រឹមត្រូវនិងគួរឱ្យទុកចិត្ត) និងដាំបណ្តុះការគិត វាចា ទម្លាប់ និងការប្រព្រឹត្តវិជ្ជមាន ដោយប្រើប្រវត្តិសាស្ត្រជាគោលប្រយោជន៍ដល់មនុស្សជាតិ។

គុណភាពនៃការបង្រៀន និងរៀន គឺពឹងអាស្រ័យជាធំលើវិធីសាស្ត្របង្រៀន និងសមត្ថភាពគ្រូបង្រៀន។ គោលវិធីនៃការបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាគឺគោលវិធីរៀនបែបរិះរក។ គោលវិធីរៀនបែបរិះរក គឺបង្កើត និងពង្រីកការឆ្ងល់ ការសួរ ការអាន ការសរសេរ និងការស្រាវជ្រាវ ដើម្បីបំពេញចំណុចខ្វះខាតរបស់អ្នកសិក្សា ដោយដាំបណ្តុះ ដុសខាត់ និងពង្រីកវិជ្ជា បំណិន និងចរិយាដែលអ្នកសិក្សាមានស្រាប់ឱ្យទៅជាប្រាជ្ញាភិវឌ្ឍន៍តាមឧបនិស្ស័យ។



ប្រភព ៖ (ALAN CRAWFORD, WENDY SAUL, SAMUEL R. MATHEWS, AND JAMES MAKINSTER, 2005) Teaching and Learning Strategies for Thinking Classrooms

ការរៀន និងបង្រៀនដើម្បីឱ្យអ្នកសិក្សាបានផលទៅជាវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា គឺប្រៀបដូចជាការដាំស្រូវដើម្បីទទួលបានផល។ ផលបានពីការរៀន គឺអ្នករៀន និងគ្រូបង្រៀនត្រូវបណ្តុះ ដាំ ដុសខាត់ ពង្រីក និងផ្សារភ្ជាប់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ទៅនឹងប្រយោជន៍នៃជីវភាពអភិវឌ្ឍន៍ និងសន្តិភាព។ រូបខាងលើពន្យល់ថា ស្រូវមួយគ្រាប់អាចដុះជាដើមស្រូវរឹងមាំ និងមានផ្លែល្អ ត្រូវការមនុស្ស ធនធាន និងវិធីបណ្តុះ ដាំ ថែ និងប្រមូលផល។




**ប្រភព៖** ប្រែសម្រួលពី Bloom Taxonomy (Benjamin Bloom, 1956)

### ៥.២- សេចក្តីណែនាំក្នុងការសរសេរសៀវភៅគោល

#### ៥.២.១- រចនាសម្ពន្ធសៀវភៅគោល

- សៀវភៅគោលគ្រប់កម្រិតថ្នាក់ត្រូវបែងចែកជាជំពូក មេរៀន ប្រធានបទ និងឧបសម្ពន្ធដែលរួមមាន គំនូសបំព្រួញ ឬសេចក្តីសង្ខេបស្តីពីកាលប្បវត្តិ ផែនទី សន្ទានុក្រម ចំណុចគន្លឹះ សិក្ខាបញ្ញត្តិ ឯកសារយោង និងឯកសារដែលគួរអានបន្ថែម
- ក្រោយបញ្ចប់ជំពូក និងមេរៀននីមួយៗត្រូវមានលំហាត់ កិច្ចការពិភាក្សា ឬស្រាវជ្រាវ ឬសំណួរបំផុសគំនិតដើម្បីវាយតម្លៃអំពីការសម្រេចលទ្ធផលសិក្សារំពឹងទុកតាមជំពូក ឬមេរៀន
- ក្នុងជំពូក និងមេរៀននីមួយៗ មានអត្ថបទ រូបភាព រូបគំនូរ ឬគំនូសបំព្រួញ និងសំណួរបំផុសគំនិតដែលឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុក។

#### ៥.២.២- គោលការណ៍សម្រាប់ការនិពន្ធ

- ការនិពន្ធត្រូវឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុក សិក្ខាបញ្ញត្តិ និងគោលវិធីរៀនបែបរិះរកតាមប្រធានបទនីមួយៗ ដោយភ្ជាប់បុព្វហេតុ (រៀបរាប់ពីកំណរកំណើតបញ្ហាដំបូង ដល់វត្តមាននៃហេតុការណ៍) ការវិវត្តនិងផលវិបាក ដើម្បីឱ្យសិស្សបានត្រិះរិះ និងស្វែងយល់ពីមូលហេតុ និងចំណោលហេតុការណ៍អនាគត
- សំណេរមេរៀនប្រវត្តិសាស្ត្រត្រូវរួមបញ្ចូលវិជ្ជាពាក់ព័ន្ធនឹងតម្រូវការ បំណិនវិភាគ និងការត្រិះរិះពិចារណា
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ ត្រូវតែស្របគ្នា ពិត និងឥតលម្អៀង
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ ត្រូវតែមានបច្ចុប្បន្នភាព និងអាចយកទៅអនុវត្តបានសម្រាប់ការរស់នៅជាក់ស្តែង
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ត្រូវមានភាពសមស្រប សម្រាប់សិស្ស ដោយពិនិត្យមើលទៅលើវ័យ សមត្ថភាព ប្រវត្តិ សាវតារ កម្រិតនៃការអាន និងរបៀប និងទម្លាប់នៃការរៀនរបស់សិស្ស
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ត្រូវមានទំនាក់ទំនងគ្នាពីមេរៀនមួយទៅមេរៀនមួយទៀត
- ខ្លឹមសារក្នុងសៀវភៅគោល និងគ្រប់កម្រិតថ្នាក់ត្រូវភ្ជាប់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទៅនឹងបរិបទសង្គម
- សេដ្ឋកិច្ច វប្បធម៌ និងនយោបាយដ៏ស្មុគស្មាញ ដែលបរិបទទាំងអស់នោះ បង្កើតជាប្រវត្តិសាស្ត្រ
- សៀវភៅប្រវត្តិវិទ្យា ត្រូវរួមបញ្ចូលទាំងរឿងរ៉ាវប្រកបដោយមោទនភាព និងរឿងរ៉ាវដែលត្រូវយកមកធ្វើជាបទពិសោធន៍ដើម្បីអាចជៀសផុតពីកំហុសច្រំដែលៗ
- ខ្លឹមសារក្នុងសៀវភៅប្រវត្តិវិទ្យា ត្រូវទ្រទ្រង់ដោយឯកសារដើមដែលមានការស្រាវជ្រាវបែបវិទ្យាសាស្ត្រ
- អ្នកសរសេរត្រូវជៀសវាងការប្រើប្រាស់ឯកសារស្រង់ពីអ៊ីនធឺណែតគ្មានឈ្មោះអ្នកនិពន្ធ ឬស្ថាប័ន
- អ្នកសរសេរត្រូវជៀសវាងការប្រើភាសាប្រមាថ ភាសារើសអើងទៅលើជាតិសាសន៍ ឬរើសអើងប្រឆាំងស្ត្រី ឬភាសាញុះញង់ដែលអាចបង្កឱ្យមានជម្លោះ ខឹងសម្បា គុំកួន និងសងសឹក
- អ្នកសរសេរត្រូវជ្រើសរើសយកផែនទី ដ្យាក្រាម គំនូរ និងរូបថត ដែលមានលក្ខណៈប្រវត្តិសាស្ត្រ និងពាក់ព័ន្ធជាមួយនឹងសំណេរមេរៀន ដើម្បីអភិវឌ្ឍគុណសម្បទារបស់អ្នកសិក្សា
- ឈ្មោះទីកន្លែងត្រូវសរសេរឱ្យបានត្រឹមត្រូវ តាមឯកសារណែនាំរបស់រាជបណ្ឌិត្យសភាកម្ពុជា
- អ្នកនិពន្ធត្រូវកំណត់គោលការណ៍សរសេរឈ្មោះមនុស្ស និងទីកន្លែងដែលគ្មានក្នុងបញ្ជីណែនាំ
- ឈ្មោះភូមិ ឃុំ ស្រុក ខេត្ត រាជធានី និងក្រុងទាំងឡាយ ក្នុងប្រទេសកម្ពុជា ត្រូវយកតាមការកំណត់ចុងក្រោយបង្អស់ របស់នាយកដ្ឋានភូមិសាស្ត្រ នៃក្រសួងមហាផ្ទៃ
- វចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ត្រូវបានប្រើជាមូលដ្ឋានក្នុងការសរសេរអក្សរខ្មែរ។

## ៦- ការវាយតម្លៃ

### ៦.១- សារៈតារ

ការវាយតម្លៃលទ្ធផលសិក្សារំពឹងទុក (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាកំណត់ក្នុងកម្មវិធីសិក្សា) ជាដំណើរការនិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតនៃការទទួលវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពីដំណើរការរៀន និងបង្រៀន ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។ ការវាយតម្លៃ គឺសំដៅរកព័ត៌មាន ឬភស្តុតាង ដើម្បីសន្និដ្ឋាន សម្រេចចិត្ត រកវិធី និងផ្តល់ធាតុចូល ជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ និងទម្រង់នៃការគ្រប់គ្រងការអប់រំ ឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា។

### ៦.២- អត្ថាវាយតម្លៃ

ការវាយតម្លៃលើលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាផ្តល់អត្ថដល់ការធានាគុណភាពអប់រំ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាព និងគុណផលនៃការគ្រប់គ្រងរបស់ប្រព័ន្ធអប់រំដូចជា ៖

- ទទួលបានព័ត៌មានអំពីឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ
- លើកទឹកចិត្តឱ្យសិស្សប្រឹងរៀនបន្ត ដោយកែលម្អចំណុចខ្សោយ ឬចំណុចខ្វះខាត ទាក់ទងនឹងឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស និងបង្រៀនរបស់គ្រូ
- ទទួលបានព័ត៌មាន ឬទិន្នន័យមូលដ្ឋាន និងភស្តុតាង ឱ្យគ្រូយកទៅវាស់ស្ទង់ប្រសិទ្ធភាពនៃដំណើរការបង្រៀន និងកែលម្អឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពនៃការបង្រៀនបន្ត
- ទទួលបានព័ត៌មានដែលអាចចែករំលែកដល់មាតាបិតា និងអាណាព្យាបាល និយោជក និងសាធារណៈ អំពីស្ថានភាពនៃការសម្រេចលទ្ធផលសិក្សារបស់សិស្ស និងលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា
- ទទួលបានព័ត៌មានអំពីប្រសិទ្ធភាព និងគុណផលនៃការគ្រប់គ្រងរបស់ប្រព័ន្ធអប់រំ។

### ៦.៣- ត្រីកោណនៃការវាយតម្លៃការសិក្សា




ដើម្បីវាស់លទ្ធផលសិក្សារំពឹងទុករបស់សិស្ស ទាំងវិជ្ជា បំណិន និងចរិយា ក្នុងគ្រប់កម្រិតសិក្សា ដែលកំណត់ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាចំណោះទូទៅពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ ដំណើរការវាយតម្លៃនឹងត្រូវទទួល

ខុសត្រូវដោយគ្រប់ភាគីពាក់ព័ន្ធក្នុងប្រព័ន្ធអប់រំ ទាំងសិស្ស មាតាបិតា គណៈកម្មការទ្រទ្រង់សាលារៀន សាលារៀន ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងភាគីពាក់ព័ន្ធនៅកម្ពុជាទាំងមូល។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សត្រូវអនុវត្តតាមគោលការណ៍ត្រីកោណវាយតម្លៃ គឺការវាយតម្លៃដើម្បីការរៀនបន្ត ការវាយតម្លៃជាការរៀនបន្ត និងការវាយតម្លៃនៃការរៀនបន្ត ដូចមានបង្ហាញក្នុងរូបត្រីកោណវាយតម្លៃខាងលើ។

### ៦.៤- ការវាយតម្លៃដើម្បីការរៀនបន្ត

**ការវាយតម្លៃដើម្បីការរៀនបន្ត** ជាដំណើរការបន្តអត់ឈប់ក្នុងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងថ្នាក់ និងមានគោលបំណងលើកកម្ពស់គុណភាពនៃការរៀនរបស់សិស្សក្នុងថ្នាក់ មិនមែនគ្រាន់តែផ្តល់ភស្តុតាងសម្រាប់កំណត់វាសនាសិស្សជាប់ ឬ ធ្លាក់ ឬឱ្យតែពិន្ទុសិស្សក្នុងថ្នាក់នោះទេ។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងថ្នាក់រៀន ត្រូវរៀបចំរួមគ្នាដោយគ្រូ សិស្សឬ/និងមិត្តរួមថ្នាក់ និងជាធាតុដ៏សំខាន់មួយនៃដំណើរការលើកកម្ពស់ ឬផ្លាស់ប្តូរឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀន និងបង្រៀនក្នុងថ្នាក់ និងក្រៅថ្នាក់ ដើម្បីជួយសិស្សឱ្យទទួលបានលទ្ធផលដូចការរំពឹងទុកក្នុងកម្មវិធីសិក្សា តាមកម្រិតថ្នាក់ ជំពូក និងមេរៀន។ ការវាយតម្លៃលទ្ធផលសិក្សាដើម្បីការរៀនបន្តនេះជាទូទៅ ផ្តោតលើលទ្ធផលសិក្សាតាមមេរៀន និងតាមជំពូក ធ្វើមិនផ្លូវការ ធ្វើបន្តជាប្រចាំ និងអាចធ្វើភ្លាមៗ ដើម្បីតាមដានឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពនៃការរៀនរបស់សិស្ស និងដើម្បីផ្ទៀងផ្ទាត់លទ្ធផលនៃការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកកំណត់ក្នុងកម្មវិធីសិក្សា។ គោលការណ៍នេះមានវិសាលភាព ក្នុងការ ៖

- ជួយគ្រូឱ្យចេះប្រើព័ត៌មានអំពីការចងចាំ ការយល់ សញ្ញា បំណិន និងឥរិយាបថរបស់សិស្សទទួលបានពីការរៀន និងបង្រៀន ក្នុងថ្នាក់ និងក្រៅថ្នាក់
- ជួយគ្រូឱ្យមានព័ត៌មានអំពីលទ្ធផលសិក្សារបស់សិស្ស ទៅតាមប្រភេទសិស្ស គិតទាំងសិស្សដែលមានតម្រូវការពិសេស ទាំងវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា កំណត់តាមមេរៀន និងជំពូក ក្នុងសៀវភៅសិក្សាគោល
- ជួយគ្រូឱ្យស្គាល់ច្បាស់អំពីឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនរបស់សិស្ស និងប្រភេទសិស្ស ដូចជាសិស្សដែលមានតម្រូវការពិសេស
- ជួយសិស្សឱ្យកែលម្អដំណើរការ ឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀនបន្ត ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់
- ជួយគ្រូឱ្យធ្វើផែនការរយៈពេលខ្លី សម្រាប់កែលម្អឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀន និងបង្រៀនទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។

### ៦.៥- ការវាយតម្លៃជាការរៀនបន្ត

**ការវាយតម្លៃជាការរៀនបន្ត** ជាដំណើរការស្វែងយល់អំពីខ្លួនឯង និងតាមដានវឌ្ឍនភាពរបស់សិស្សដោយសិស្ស ក្នុងន័យស្វ័យវាយតម្លៃ និងឆ្លុះបញ្ចាំងពីការសម្រេចលទ្ធផលសិក្សា និងបង្កើតផែនការរៀនបន្តឱ្យសម្រេចលទ្ធផលសិក្សាដូចមានកំណត់ក្នុងកម្មវិធីសិក្សា។

- សិស្សបានរៀនអ្វីខ្លះ? មិនទាន់ចាំអ្វីខ្លះ មិនទាន់អាចភ្ជាប់លទ្ធផលសិក្សាទៅនឹងជីវភាពប្រចាំថ្ងៃ?
- សិស្សអាចជួយខ្លួនឯង ជួយសិស្សគ្នាឯង និងត្រូវការជំនួយអ្វីបន្ថែម ដើម្បីលើកកម្ពស់ការទទួលខុសត្រូវរបស់ខ្លួនសម្រាប់ការរៀនបន្ត និងសម្រាប់រកទិសដៅរៀនទៅមុខទៀត ឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សា
- សិស្សមាន ឬនៅខ្វះឥរិយាបថ ទម្លាប់ វិធី សកម្មភាព និងត្រូវការធាតុចូលអ្វីខ្លះដើម្បីជាជំនួយក្នុងការរៀនបន្តឱ្យទទួលបានលទ្ធផល ដូចការរំពឹងទុកក្នុងកម្មវិធីសិក្សា

លទ្ធផលទាំងនេះគឺសម្រាប់ជួយគ្រូបង្រៀន និងសិស្សក្នុងការធ្វើផែនការសិក្សាបន្តរយៈពេលខ្លី និងមធ្យមក្នុងការផ្គត់ផ្គង់ធាតុចូល និងតម្រូវការរបស់សិស្ស និងគ្រូ ក្នុងការបង្រៀន និងរៀនបន្ត ឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុកដូចមានចែងក្នុងកម្មវិធីសិក្សា។

### ៦.៦- ការវាយតម្លៃនៃការរៀន

**ការវាយតម្លៃនៃការរៀន** ជាដំណើរការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស តាមកាលកំណត់ជាក់លាក់មួយ មានត្រីមាស ឆមាស និងប្រចាំឆ្នាំ គឺក្រោយពេលរៀន និងបង្រៀនបញ្ចប់បណ្ដុំនៃលទ្ធផលសិក្សាក្នុងកម្មវិធីសិក្សាកម្រិតណាមួយ។ ការវាយតម្លៃនៃការរៀនជាការទទួលខុសត្រូវរបស់សាលារៀន ការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងក្រសួងអប់រំ យុវជន និងកីឡា និងមានទិសដៅ ៖

- ផ្ដល់ភស្តុតាងឱ្យគ្រូ សាលា និងប្រព័ន្ធអប់រំតាមកម្រិតនីមួយៗ វាស់លទ្ធផលសិក្សារបស់សិស្ស ធៀបនឹងលទ្ធផលសិក្សាកំណត់ក្នុងកម្មវិធីសិក្សាជាតិ
- បញ្ជូនព័ត៌មានដល់មាតាបិតា អាណាព្យាបាល និយោជក និងសាធារណៈ អំពីការសម្រេចលទ្ធផលសិក្សារំពឹងទុករបស់សិស្ស
- ផ្ដល់ទិន្នន័យចាំបាច់សម្រាប់ស្ថាប័នទទួលបន្ទុកកិច្ចការអប់រំ និងក្រសួងអប់រំ យុវជន និងកីឡា និងភាគីពាក់ព័ន្ធសម្រាប់រៀបចំផែនការរយៈពេលមធ្យម និងវែងក្នុងការកែលម្អកម្មវិធីសិក្សា និងបណ្ដុះបណ្ដាលគ្រូ។

## ៧- តារាងកម្មវិធីសិក្សា

### ៧.១- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១០

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង | |
|---|---|---|---|
| | | ទ្រឹ. ស | ទ្រឹ. សស |
| **ជំពូកទី១ : ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទតំបន់ និងពិភពលោក** | | | |
| **មេរៀនទី១ : ប្រវត្តិវិទ្យា និងលក្ខណៈវិនិច្ឆ័យ**<br>**សិក្សាបញ្ញត្តិ :** ប្រវត្តិសាស្ត្រ ភាពខុសគ្នា ភស្តុតាង<br>**មាតិកា :**<br>១.១- ទស្សនៈស្តីពីប្រវត្តិសាស្ត្រ<br>សំណួរត្រិះរិះ :<br>• តើមានការពន្យល់យ៉ាងណាខ្លះស្ដីពីនិយមន័យប្រវត្តិសាស្ត្រ?<br>១.២- ប្រវត្តិសាស្ត្រ ឬប្រវត្តិវិទ្យា?<br>សំណួរត្រិះរិះ :<br>• តើប្រវត្តិសាស្ត្រ និងប្រវត្តិវិទ្យាជាអ្វី?<br>១.៣- ឯកសារ និងភស្តុតាងប្រវត្តិសាស្ត្រខ្មែរ<br>ក. បុរាណវត្ថុ<br>ខ. ឯកសារចិន | **វិជ្ជាសម្បទា**<br>- ពិភាក្សាពីនិយមន័យផ្សេងៗគ្នានៃប្រវត្តិសាស្ត្រ និងភាពដូច និងខុសគ្នារវាងប្រវត្តិវិទ្យា និងប្រវត្តិសាស្ត្រ។<br>**បំណិនសម្បទា**<br>- ពន្យល់ពីតួនាទី និងសារៈសំខាន់នៃការសិក្សាប្រវត្តិសាស្ត្រ<br>- វិនិច្ឆ័យពីភាពត្រឹមត្រូវ និងអព្យាក្រឹតនៃឯកសារ និងភស្តុតាងក្នុងការសិក្សាពីប្រវត្តិសាស្ត្រខ្មែរ។<br>**ចរិយាសម្បទា** | ៤ ម៉ | ៨ ម៉ |

| | | | |
|---|---|---|---|
| គ. សិលាចារឹក<br>ឃ. រាជពង្សាវតារ<br>ង. កំណត់ហេតុរបស់ពួកអឺរ៉ុប<br>ច. ឯកសាររស់<br>សំណួរគន្លឹះ :<br>• តើឯកសារ និងភស្តុតាងដែលយកមកអះអាងអំពីប្រវត្តិសាស្ត្រខ្មែរអាចយកជាការបានដែរឬទេ? ព្រោះហេតុអ្វី?<br>១.៤- សារៈសំខាន់នៃប្រវត្តិសាស្ត្រ<br>សំណួរគន្លឹះ :<br>• តើការសិក្សាពីប្រវត្តិសាស្ត្រផ្តល់ប្រយោជន៍អ្វីខ្លះ? | - ជ្រើសរើសអត្ថបទប្រវត្តិសាស្ត្រដែលអាចជឿជាក់បាន ដោយផ្អែកលើអំណះអំណាងបុរាណវិទ្យា ឬវិទ្យាសាស្ត្រ។ | | |
| **មេរៀនទី២ : បុរេប្រវត្តិសាស្ត្រកម្ពុជា និងអន្តរកម្ម**<br>**សិក្សាបញ្ញត្តិ :** ដើមកំណើត ទំនាក់ទំនង ឥទ្ធិពលបរទេស ពាណិជ្ជកម្ម ការដោះដូរសេដ្ឋកិច្ច កសិកម្ម សិប្បកម្ម<br>**មាតិកា :**<br>២.១- ជនជាតិខ្មែរ និងដើមកំណើត<br>ក. ដើមកំណើតខ្មែរតាមរបកគំហើញបុរាណវិទ្យា<br>ខ. ដើមកំណើតខ្មែរតាមរយៈភាសាវិទ្យា<br>សំណួរគន្លឹះ :<br>• តើខ្មែរមានដើមកំណើតតាំងពីពេលណាមក? តើមានការពន្យល់ខុសគ្នាយ៉ាងដូចម្តេចខ្លះទាក់ទងនឹងដើមកំណើតរបស់ជនជាតិខ្មែរលើទឹកដីខ្មែរបច្ចុប្បន្ន?<br>២.២- ការគ្រប់គ្រងរដ្ឋ និងសង្គម-សេដ្ឋកិច្ច<br>សំណួរគន្លឹះ :<br>• តើការគ្រប់គ្រងរដ្ឋសម័យបុរេប្រវត្តិមានទំនាក់ទំនងយ៉ាងដូចម្តេចចំពោះសង្គម និងសេដ្ឋកិច្ចកម្ពុជា?<br>២.៣- ការដោះដូរទំនិញ<br>សំណួរគន្លឹះ :<br>• តើការដោះដូរទំនិញក្នុងស្រុក និងក្រៅស្រុកមានលក្ខណៈយ៉ាងដូចម្តេចខ្លះ?<br>២.៤- ទំនាក់ទំនង និងការអភិវឌ្ឍវប្បធម៌<br>សំណួរគន្លឹះ :<br>• តើប្រជាជនខ្មែរបានទទួលយកវប្បធម៌បរទេសអ្វីខ្លះ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរក្សាប្រពៃណី និងទំនៀមទម្លាប់ក្នុងស្រុកអំឡុងពេលអន្តរសកម្ម។<br>**បំណិនសម្បទា**<br>- ពន្យល់ពីឥទ្ធិពលនៃទំនាក់ទំនងជាមួយបរទេសលើរបៀបរស់នៅ ប្រពៃណី ទំនៀមទម្លាប់ និងរបៀបធ្វើកសិកម្ម សិប្បកម្ម និងពាណិជ្ជកម្មរបស់ជនជាតិខ្មែរ<br>- វិភាគពីដើមកំណើតជនជាតិ និងអរិយធម៌ខ្មែរសម័យបុរេប្រវត្តិ។<br>**ចរិយាសម្បទា**<br>- ចងក្រងព័ត៌មានពីបន្សំវប្បធម៌ខ្មែរ និង វប្បធម៌បរទេសដែលផ្តល់ផលវិជ្ជមានដល់ខ្មែរ។ | ៧ ម៉ | ១៤ ម៉ |

| | | | |
|---|---|---|---|
| ដើម្បីយកមកផ្សំជាមួយ នឹងវប្បធម៌របស់ខ្លួន? តើការរួមផ្សំវប្បធម៌នេះមានលក្ខណៈបែបណា? | | | |
| **មេរៀនទី៣ : ហ្វូណន និងមហាអំណាចក្នុងតំបន់**<br>**សិក្សាបញ្ញត្តិ** : មហាអំណាច អន្តរទំនាក់ទំនង រូបិយវត្ថុ មោទនភាព គោលគំនិត«ចាស់និងថ្មី» ភស្តុតាង<br>**មាតិកា :**<br>៣.១- នគរភ្នំ ហ្វូណន ហ្វូណាន ឬសុវណ្ណភូមិ?<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាមានការហៅឈ្មោះអាណាចក្រខ្មែរថានគរភ្នំ ហ្វូណន ហ្វូណាន ឬ សុវណ្ណភូមិ?<br>៣.២- វ្យាធបុរៈ<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាមានឈ្មោះរាជធានីវ្យាធបុរៈច្រើនកន្លែង?<br>៣.៣- ភូមិសាស្ត្រ និងអំណាចសេដ្ឋកិច្ច<br>សំណួរត្រិះរិះ :<br>• តើទីតាំងភូមិសាស្ត្ររបស់កម្ពុជាមានអំណោយផលយ៉ាងដូចម្ដេចខ្លះក្នុងការជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា?<br>៣.៤- គោលនយោបាយអភិវឌ្ឍន៍<br>ក. ផលិតផលក្នុងស្រុក<br>ខ. នយោបាយទឹក<br>គ. នគរូបនីយកម្ម៖ ការរៀបចំទីក្រុង និង ស្ថាបត្យកម្ម<br>ឃ. ប្រព័ន្ធហិរញ្ញវត្ថុ និងពាណិជ្ជកម្ម<br>ង. ការអប់រំ និងកំណត់ត្រា<br>ច. សុខដុមភាពសាសនា<br>សំណួរត្រិះរិះ :<br>• តើការអភិវឌ្ឍលើផ្នែកអ្វីខ្លះដែលជំរុញឱ្យកម្ពុជាក្លាយជាប្រជាជាតិឈានមុខគេក្នុងតំបន់?<br>៣.៥- អន្តរទំនាក់ទំនងរវាងខ្មែរ និងឥណ្ឌា<br>សំណួរត្រិះរិះ :<br>• តើខ្មែរទទួលឥទ្ធិពលឥណ្ឌាដោយរបៀបណា? តើឥទ្ធិពលនៃវប្បធម៌ឥណ្ឌាបានធ្វើឱ្យមានការផ្លាស់ប្ដូរអ្វីខ្លះក្នុងនយោបាយ សង្គម និងសេដ្ឋកិច្ចខ្មែរ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីហេតុផល និងភស្តុតាងនៃការហៅឈ្មោះអាណាចក្រខ្មែរក្នុងសម័យហ្វូណន<br>- បង្ហាញពីគោលគំនិត «ចាស់ និងថ្មី» ក្នុងការដាក់ឈ្មោះរាជធានី។<br>**បំណិនសម្បទា**<br>- វិភាគពីឥទ្ធិពលវប្បធម៌ឥណ្ឌានិងចិនមកលើអរិយធម៌ខ្មែរ<br>- វិភាគពីកត្តាដែលធ្វើឱ្យហ្វូណនរីកចម្រើន (សេដ្ឋកិច្ច ពាណិជ្ជកម្ម នយោបាយទឹក សុខដុមនីយកម្ម<br>- វិភាគពីមូលហេតុនៃការបញ្ចប់សម័យកាលហ្វូណន។<br>**ចរិយាសម្បទា**<br>- គោរពស្រឡាញ់បុព្វបុរសខ្មែរ និងថែរក្សាអរិយធម៌ហ្វូណន។ | ៨ ម៉ | ១៦ ម៉ |

| | | | |
|---|---|---|---|
| ៣.៦- អន្តរទំនាក់ទំនងរវាងខ្មែរ និងចិន<br>សំណួរត្រិះរិះ :<br>• តើទំនាក់ទំនងខ្មែរ និងចិនបានធ្វើឱ្យមានការផ្លាស់ប្តូរអ្វីខ្លះក្នុងសង្គម និងសេដ្ឋកិច្ចខ្មែរ?<br>៣.៧- អន្តរទំនាក់ទំនងរវាងខ្មែរ និងអាស៊ីអាគ្នេយ៍<br>សំណួរត្រិះរិះ :<br>• តើអន្តរទំនាក់ទំនងរវាងខ្មែរ និងរដ្ឋក្នុងតំបន់មានសារៈសំខាន់ និងកត្តាប្រឈមអ្វីខ្លះចំពោះកម្ពុជា?<br>៣.៨- ខ្មែរ និងអាណាចក្រផ្សេងទៀត<br>សំណួរត្រិះរិះ :<br>• តើទំនាក់ទំនងជាមួយបរទេសបានផ្តល់ប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ?<br>៣.៩- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកម្ពុជាក្លាយជាមហាអំណាចនៅអាស៊ីអាគ្នេយ៍ក្នុងសម័យហ្វូណនដោយរបៀបណា? | | | |
| **មេរៀនទី៤ : ចេនឡា និងដំណើរឆ្ពោះទៅរក ឧត្តមភាព**<br>**សិក្សាបញ្ញត្តិ** : មោទនភាព មហាអំណាច រូបិយវត្ថុ អន្តរទំនាក់ទំនង ភស្តុតាង អំណះអំណាង<br>**មាតិកា :**<br>៤.១- ព្រឹត្តការណ៍សំខាន់ៗក្នុងស្រុក<br>សំណួរត្រិះរិះ :<br>• តើមានព្រឹត្តការណ៍ក្នុងស្រុកអ្វីខ្លះដែលប៉ះពាល់ដល់សេដ្ឋកិច្ច វប្បធម៌ និងនយោបាយចេនឡា?<br>៤.២- ព្រឹត្តការណ៍សំខាន់ៗក្នុងតំបន់ និងពិភពលោក និងផលប៉ះពាល់លើចេនឡា<br>សំណួរត្រិះរិះ :<br>• តើមានព្រឹត្តការណ៍ក្នុងតំបន់ និងពិភពលោកអ្វីខ្លះដែលប៉ះពាល់ដល់សេដ្ឋកិច្ច វប្បធម៌ និងនយោបាយសម័យចេនឡា?<br>៤.៣- ប្រាសាទថ្ម និងការវិវត្ត<br>សំណួរត្រិះរិះ :<br>• តើហេតុអ្វីបានជាព្រះមហាក្សត្រខ្មែរបុរាណកសាងប្រាសាទថ្ម? តើរចនាបថប្រាសាទថ្មមានការវិវត្ត | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីព្រឹត្តការណ៍ក្នុង និងក្រៅប្រទេសដែលប៉ះពាល់ដល់ការប្រែប្រួលសេដ្ឋកិច្ច វប្បធម៌ និងនយោបាយចេនឡា<br>- ពន្យល់ពីការកើតឡើងនៃសំណង់ប្រាសាទថ្ម និងសារៈសំខាន់នៃប្រាសាទថ្ម សម្រាប់ព្រះមហាក្សត្រ និងប្រជាជនខ្មែរ។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបលក្ខណៈសំណង់នៃប្រាសាទក្នុងសម័យហ្វូណន និងសម័យចេនឡា<br>- ចង្អុលបង្ហាញពីលក្ខណៈពិសេសនៃប្រាសាទសំបូរព្រៃគុក និងការដាក់បញ្ចូលជាបេតិកភណ្ឌពិភពលោក។<br>**ចរិយាសម្បទា** | ៦ ម៉ | ១២ ម៉ |

| | | | |
|---|---|---|---|
| យ៉ាងដូចម្ដេចខ្លះពីសម័យ ហ្វូណន ដល់សម័យចេនឡា?<br>៤.៤- បេតិកភណ្ឌពិភពលោក និងប្រាសាទសំបូរព្រៃគុក<br>សំណួរត្រិះរិះ :<br>• តើអ្វីទៅជាបេតិកភណ្ឌពិភពលោក? តើលក្ខខណ្ឌអ្វីខ្លះដែលជំរុញឱ្យប្រាសាទសំបូរព្រៃគុកបានក្លាយជាបេតិកភណ្ឌពិភពលោក?<br>៤.៥- ភស្តុតាងសរសេរ និងប្រវត្តិចេនឡា<br>សំណួរត្រិះរិះ :<br>• តើភាពស្រពេចស្រពិលនៃប្រវត្តិសាស្ត្រសម័យចេនឡាបណ្ដាលមកពីអ្វី?<br>• តើត្រូវធ្វើដូចម្ដេចដើម្បីជៀសវាងកំហុសច្រំដែល?<br>៤.៦- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកម្ពុជាមានលក្ខណៈ និងឥរិយាបថបែបណាក្នុងការទាញយកផលប្រយោជន៍ពីបម្រែបម្រួលក្នុងតំបន់ និងពិភពលោក? | - សរសេរអត្ថបទខ្លីពីបញ្ហាខ្វះឯកសារសរសេរ ទាក់ទងនឹងសម័យចេនឡា និងភាពស្រពេចស្រពិលនៃប្រវត្តិសាស្ត្រសម័យចេនឡា។ | | |
| **មេរៀនទី៥ : ចក្រភពអង្គរ និងមហាអំណាចក្នុងតំបន់**<br>**សិក្សាបញ្ញត្តិ :** មហាអំណាច ភាពម្ចាស់ការ ឥទ្ធិពលខ្មែរ ឱនភាព និរន្តរភាព តម្លៃសកល<br>**មាតិកា :**<br>៥.១- ពីអាណាចក្រក្លាយជាមហាអំណាចតំបន់<br>ក. ភូមិសាស្ត្រនយោបាយ<br>សំណួរត្រិះរិះ :<br>• តើកត្តាភូមិសាស្ត្រនយោបាយខ្មែរចូលរួមចំណែកយ៉ាងដូចម្ដេចក្នុងការកសាងអរិយធម៌ខ្មែរដ៏រុងរឿង?<br>ខ. សិល្បៈក្នុងការដឹកនាំ<br>សំណួរត្រិះរិះ ៖<br>• តើលទ្ធិនិងសិល្បៈដឹកនាំរដ្ឋខ្មែរមានភាពលេចធ្លោរជាងរដ្ឋដទៃក្នុងតំបន់យ៉ាងដូចម្ដេចខ្លះ?<br>គ. ចក្រភពអង្គរ និងឥទ្ធិពល<br>សំណួរត្រិះរិះ :<br>• តើចក្រភពអង្គរអាចវាតទីអំណាច និងឥទ្ធិពលខ្លួនដោយរបៀបណា? | **វិជ្ជាសម្បទា**<br>- ពន្យល់ពីកត្តាដែលធ្វើឱ្យចក្រភពអង្គរក្លាយជាមហាអំណាចក្នុងតំបន់<br>- បង្ហាញពីកត្តាដែលធ្វើឱ្យចក្រភពអង្គររក្សាភាពម្ចាស់ការបានពីសតវត្សរ៍ទី៩ ដល់ទី១៥។<br>**បំណិនសម្បទា**<br>- ចង្អុលបង្ហាញពីសម្មតិកម្មដែលបញ្ជាក់ថា ចក្រភពអង្គរ ជាមហាអំណាចក្នុងតំបន់<br>- វិភាគពីបម្រែបម្រួលក្នុងតំបន់ និងផលប៉ះពាល់ដល់ចក្រភពអង្គរ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីតម្លៃសាកលនៃស្នាព្រះហស្តរបស់ព្រះមហាក្សត្រខ្មែរក្នុងសម័យចក្រភពអង្គរ | ១០ម៉ | ២០ ម៉ |

| | | | |
|---|---|---|---|
| ៥.២- អង្គរ និងភាពម្ចាស់ការ<br>ក. សាមគ្គីភាព និងការបន្តនិរន្តភាព<br>ខ. គំនិតច្នៃប្រឌិត និងការអភិវឌ្ឍ<br>គ. ការបំពេញតួនាទី និងគោរពច្បាប់ទម្លាប់<br>ឃ. សង្គ្រាម និងមនសិការស្នេហាជាតិ<br>ង. មហាអំណាច និងសម្ព័ន្ធភាព<br>សំណួរត្រិះរិះ :<br>• តើកត្តាអ្វីខ្លះដែលធ្វើឱ្យចក្រភពអង្គររក្សាភាពម្ចាស់ការបានពីសតវត្សរ៍ទី៩ ដល់ទី១៥?<br>៥.៣- ឥទ្ធិពលខ្មែរក្នុងតំបន់<br>ក. ភាសា និងអក្សរខ្មែរក្នុងតំបន់<br>ខ. សិល្បៈ និងស្ថាបត្យកម្មខ្មែរក្នុងតំបន់<br>គ. វិស័យអប់រំ និងការផ្សព្វផ្សាយ<br>ឃ. ផលិតផលខ្មែរ និងពាណិជ្ជកម្មក្នុងតំបន់<br>ង. សួយសារអាករ និងសម្ព័ន្ធភាព<br>ច. សង្គ្រាម និងការត្រួតត្រា<br>ឆ. រាជធានីអង្គរ និងការប៉ុនប៉ងពីរដ្ឋជិតខាង<br>សំណួរត្រិះរិះ :<br>• តើកត្តាអ្វីខ្លះដែលបញ្ជាក់ថាអង្គរជាមហាអំណាចក្នុងតំបន់? មានអ្វីជាភស្តុតាង?<br>៥.៤- ឥទ្ធិពល និងបម្រែបម្រួលក្នុងស្រុក<br>ក. បម្រែបម្រួលផ្ទៃក្នុង និងឱនភាព?<br>ខ. ឥទ្ធិពលនៃបម្រែបម្រួលតំបន់ និងពិភពលោក<br>សំណួរត្រិះរិះ :<br>• តើនយោបាយក្រៅប្រទេសរបស់ខ្មែរ និងនយោបាយរបស់ប្រទេសជិតខាងនិងចិនជះឥទ្ធិពលអ្វីខ្លះដល់ឱនភាពរបស់អាណាចក្រអង្គរ?<br>៥.៥- ស្នាព្រះហស្តនៃចក្រភពអង្គរ និងតម្លៃសកល<br>ក. រមណីយដ្ឋានអង្គរ និងបេតិកភណ្ឌពិភពលោក<br>ខ. រមណីយដ្ឋានប្រាសាទព្រះវិហារ និងបេតិកភណ្ឌពិភព<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាស្នាដៃសិល្បៈ និងស្ថាបត្យកម្មសម័យអង្គរមានតម្លៃអមតៈចំពោះកម្ពុជា និង | - សរសេរអត្ថបទស្តីពីអត្ថប្រយោជន៍នៃស្នាព្រះហស្តផ្នែកស្ថាបត្យកម្ម និងវប្បធម៌សម័យកាលចក្រភពអង្គរ ចំពោះកូនចៅខ្មែរសម័យកាលបច្ចុប្បន្ន និងអនាគត។ | | |

| | | | |
|---|---|---|---|
| ពិភពលោក?<br>៥.៦- ចូរត្រិះរិះ?<br>សំណួរត្រិះរិះ :<br>• តើស្ពាព្រះហស្តផ្នែកស្ថាបត្យកម្ម និងវប្បធម៌សម័យចក្រភពអង្គរ បានបម្រើប្រយោជន៍អ្វីខ្លះដល់មនុស្សជាតិ នាពេលបច្ចុប្បន្ន និងអនាគត? | | | |
| **ជំពូកទី២: ប្រវត្តិសាស្ត្រតំបន់ "អាណានិគម និងបម្រែបម្រួលសង្គមអាស៊ីអាគ្នេយ៍ (សតវត្សរ៍ទី១៩-២០)"** | | | |
| **មេរៀនទី១ :  អាណានិគមរបស់អឺរ៉ុបនៅអាស៊ីអាគ្នេយ៍**<br>**សិក្សាបញ្ញត្តិ** : អាណានិគម អន្តរាគមន៍ ការគ្រប់គ្រងផ្ទាល់ ការគ្រប់គ្រងមិនផ្ទាល់ ឥទ្ធិពល ផលប៉ះពាល់ ការតស៊ូប្រឆាំង ការសហការ ទំនើបកម្ម កំណែទម្រង់<br>**មាតិកា :**<br>១.១- ការដាក់អាណានិគមរបស់អឺរ៉ុបនៅអាស៊ីអាគ្នេយ៍ និងមូលហេតុ<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាអឺរ៉ុបដាក់អាណានិគមលើអាស៊ីអាគ្នេយ៍?<br>១.២- ការតបតរបស់អ្នកម្ចាស់ស្រុកទៅនឹងមហាអំណាចអាណានិគម<br>សំណួរត្រិះរិះ :<br>• តើអាស៊ីអាគ្នេយ៍តបតយ៉ាងដូចម្តេចចំពោះការដាក់អាណានិគមរបស់អឺរ៉ុប?<br>១.៣- អាណានិគម និងឥទ្ធិពល<br>សំណួរត្រិះរិះ :<br>• តើការដាក់អាណានិគមបានជះឥទ្ធិពលអ្វីខ្លះដល់អាស៊ីអាគ្នេយ៍?<br>១.៤-  ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើទស្សនៈ និងការយល់ឃើញខុសគ្នាបណ្តាលឱ្យមានផលវិបាកអ្វីខ្លះ?<br>• តើត្រូវធ្វើដូចម្តេចដើម្បីរក្សាភាពថ្លៃថ្នូរ សន្តិភាព និងជៀសវាងទំនាស់ក្នុងពេលមានទស្សនៈ និងការយល់ឃើញខុសគ្នា? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃការពង្រីកអំណាចរបស់អឺរ៉ុបលើតំបន់អាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលរបស់អឺរ៉ុបនៅអាស៊ីអាគ្នេយ៍<br>- វាយតម្លៃការតបតរបស់អ្នកម្ចាស់ស្រុកចំពោះការពង្រីកអំណាច និងឥទ្ធិពលអឺរ៉ុប។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីជម្លោះបណ្តាលមកពីមិនគោរព និងផ្តល់តម្លៃ ចំពោះទស្សនៈផ្ទុយគ្នា។ | ៥ ម៉ | ១០ ម៉ |

| | | | |
|---|---|---|---|
| **មេរៀនទី ២ : ជ្រោយម៉ាឡាយូ និងអាណានិគមរបស់អង់គ្លេស**<br>**សិក្សាបញ្ញត្តិ :** ការគ្រប់គ្រង អាណានិគម ផលប៉ះពាល់ ការគ្រប់គ្រងផ្ទាល់ ការគ្រប់គ្រងមិនផ្ទាល់ ឥទ្ធិពល អន្តរាគមន៍ តស៊ូ សហការ ទំនើបកម្ម កំណែទម្រង់<br>**មាតិកា :**<br>២.១- ការដាក់អាណានិគមរបស់អង់គ្លេសនៅជ្រោយម៉ាឡាយូ និងមូលហេតុ<br>សំណួរត្រិះរិះ :<br>• អ្វីទៅជាមូលហេតុចម្បងនៃការដាក់អាណានិគមរបស់អង់គ្លេសលើជ្រោយម៉ាឡាយូ?<br>២.២- ប្រជាជនម៉ាឡេ និងអាណានិគមរបស់អង់គ្លេស<br>សំណួរត្រិះរិះ :<br>• តើប្រជាជនម៉ាឡេតបតយ៉ាងដូចម្តេចចំពោះការដាក់អាណានិគមរបស់អង់គ្លេស?<br>២.៣- អាណានិគមអង់គ្លេស និងវឌ្ឍនភាពជ្រោយម៉ាឡាយូ<br>សំណួរត្រិះរិះ :<br>• តើការគ្រប់គ្រងរបស់អង់គ្លេសបាននាំមកនូវវឌ្ឍនភាពកម្រិតណាចំពោះជ្រោយម៉ាឡាយូ?<br>២.៤- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើអាណានិគមអង់គ្លេសនៅជ្រោយម៉ាឡាយូបង្កផលវិបាកអ្វីខ្លះ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃការពង្រីកអំណាចរបស់អង់គ្លេសលើជ្រោយម៉ាឡាយូ។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យពីមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលរបស់អង់គ្លេសនៅជ្រោយម៉ាឡាយូ<br>- វាយតម្លៃពីការតបតរបស់ប្រជាជនម៉ាឡេចំពោះការពង្រីកអំណាច និងឥទ្ធិពលរបស់អង់គ្លេស។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីផលវិបាកវិជ្ជមាន និងអវិជ្ជមាននៃអាណានិគមអង់គ្លេសលើជ្រោយម៉ាឡាយូ។ | ៥ ម៉ | ១០ ម៉ |
| **មេរៀនទី ៣ : វៀតណាម និងអាណានិគមរបស់បារាំង**<br>**សិក្សាបញ្ញត្តិ :** ការគ្រប់គ្រង អាណានិគម ការគ្រប់គ្រងផ្ទាល់ ការគ្រប់គ្រងមិនផ្ទាល់ ផលប៉ះពាល់ ឥទ្ធិពល អន្តរាគមន៍ ការតស៊ូ ការសហការ ទំនើបកម្ម កំណែទម្រង់<br>**មាតិកា :**<br>៣.១- ការដាក់អាណានិគមរបស់បារាំងនៅវៀតណាម និងមូលហេតុ<br>សំណួរត្រិះរិះ :<br>• មូលហេតុអ្វីខ្លះដែលបារាំងដាក់អាណានិគមលើវៀតណាម?<br>៣.២- ការតបតរបស់ប្រជាជនវៀតណាមទៅនឹងការវាត | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃការពង្រីកអំណាចរបស់បារាំងលើប្រទេសវៀតណាម។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលរបស់បារាំងនៅវៀតណាម<br>- វាយតម្លៃការតបតរបស់ជនជាតិវៀតណាមចំពោះការពង្រីកអំណាច និងឥទ្ធិពលបារាំង។ | ៥ ម៉ | ១០ ម៉ |

| | | | |
|---|---|---|---|
| អំណាចរបស់បារាំង<br>សំណួរត្រិះរិះ :<br>• តើប្រជាជនវៀតណាមតបតយ៉ាងដូចម្ដេចចំពោះការពង្រីកអំណាចរបស់បារាំងនៅវៀតណាម?<br>៣.៣- អាណានិគមបារាំង និងកំណែទម្រង់<br>សំណួរត្រិះរិះ :<br>• តើការគ្រប់គ្រងរបស់បារាំងបាននាំមកនូវផលវិជ្ជមាន និងអវិជ្ជអ្វីខ្លះចំពោះវៀតណាម?<br>៣.៤- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកត្តាអ្វីខ្លះដែលអាចពន្យល់បានថា ជនជាតិវៀតណាមមានភាពវៃឆ្លាត និងក្លាហានក្នុងការដោះស្រាយបញ្ហានៃការពង្រីកអំណាចរបស់បារាំងលើទឹកដីខ្លួន? | **ចរិយាសម្បទា**<br>- សន្និដ្ឋានរួមប្រកបដោយភាពយុត្តិធម៌ស្ដីពីភាពវៃឆ្លាត និងក្លាហានរបស់ជនជាតិវៀតណាមក្នុងការតបតចំពោះអាណានិគមនិយមវៀតណាម។ | | |
| **មេរៀនទី ៤ :   ឥណ្ឌូណេស៊ី និងអាណានិគមហូឡង់**<br>**សិក្សាបញ្ញត្តិ :** ការគ្រប់គ្រង អាណានិគម ការគ្រប់គ្រងផ្ទាល់ ការគ្រប់គ្រងមិនផ្ទាល់ ផលប៉ះពាល់ ឥទ្ធិពល អន្តរាគមន៍ ការតស៊ូ សហការ ទំនើបកម្ម កំណែទម្រង់<br>**មាតិកា :**<br>៤.១- ឥណ្ឌូណេស៊ី និងការដាក់អាណានិគមរបស់ហូឡង់<br>សំណួរត្រិះរិះ :<br>• តើមូលហេតុអ្វីខ្លះដែលហូឡង់ដាក់អាណានិគមលើឥណ្ឌូណេស៊ី?<br>៤.២- ប្រជាជនឥណ្ឌូណេស៊ី និងការរាតអំណាចរបស់ហូឡង់<br>សំណួរត្រិះរិះ :<br>• តើប្រជាជាជនឥណ្ឌូណេស៊ីតបតយ៉ាងដូចម្ដេចចំពោះការពង្រីកអំណាចរបស់ហូឡង់លើទឹកដីឥណ្ឌូណេស៊ី?<br>៤.៣- អាណានិគមហូឡង់ និងកំណែទម្រង់<br>សំណួរត្រិះរិះ :<br>• តើការគ្រប់គ្រងរបស់ហូឡង់បាននាំមកនូវឥទ្ធិពលខ្លះចំពោះឥណ្ឌូណេស៊ី?<br>៤.៤- ចូរត្រិះរិះ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃការពង្រីកអំណាចរបស់ហូឡង់លើឥណ្ឌូណេស៊ី។<br>**បំណិនសម្បទា**<br>- វិនិច្ឆ័យពីមូលហេតុនៃការពង្រីកអំណាច និងឥទ្ធិពលរបស់ហូឡង់នៅឥណ្ឌូណេស៊ី<br>- វាយតម្លៃការតបតរបស់ជនជាតិឥណ្ឌូណេស៊ីចំពោះការពង្រីកអំណាច និងឥទ្ធិពលហូឡង់។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមប្រកបដោយភាពយុត្តិធម៌ស្ដីពីទំហំនៃការរួមចំណែករបស់ហូឡង់ក្នុងការកែទម្រង់ឥណ្ឌូណេស៊ី និងផលវិបាកដែលហូឡង់បន្សល់ទុក។ | ៥ ម៉ | ១០ ម៉ |

| | | | |
|---|---|---|---|
| សំណួរត្រិះរិះ :<br>• តើមានហេតុផលអ្វីខ្លះពន្យល់ពីភាពវៃឆ្លាត និង ក្លាហានរបស់វៀតណាមក្នុងការដោះស្រាយបញ្ហា នៃការពង្រីកអំណាចរបស់បារាំងលើទឹកដីខ្លួន? | | | |

| ជំពូកទី ៣ : ប្រវត្តិសាស្ត្រពិភពលោក "សង្គ្រាមលោកលើកទី១ និងវិបត្តិនៅអឺរ៉ុប (១៩១៤-១៩៣៩)" | | | |
|---|---|---|---|
| **មេរៀនទី១ : មហាអំណាចមុនសង្គ្រាមលោក លើកទី១ និងវិបត្តិពិភពលោក**<br>**សិក្សាបញ្ញត្តិ :** ការប្រកួតប្រជែង អំណាច ប្លុកយោធា វិបត្តិ<br>**មាតិកា :**<br>១.១- មហាអំណាច និងការប្រកួតប្រជែង<br>សំណួរត្រិះរិះ :<br>• តើមូលហេតុអ្វីខ្លះដែលបណ្ដាលឱ្យមានការប្រកួតប្រជែងរវាងប្រទេសមហាអំណាច?<br>១.២- ការបង្កើតប្លុកយោធា និងសន្តិសុខពិភពលោក<br>សំណួរត្រិះរិះ :<br>• តើការចងសម្ព័ន្ធមិត្ត និងប្លុកយោធារបស់ប្រទេសមហាអំណាចផ្ដល់ផលប៉ះពាល់យ៉ាងដូចម្ដេចខ្លះចំពោះសន្តិសុខពិភពលោក?<br>១.៣- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើយុវជនចូលរួមទប់ស្កាត់អំពើហិង្សាប្រដាប់អាវុធតាមមធ្យោបាយអ្វីខ្លះ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីមូលហេតុនៃការប្រកួតប្រជែងរបស់មហាអំណាច។<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុនៃការបង្កើតប្លុកយោធាការចងសម្ព័ន្ធមិត្ត និងផលប៉ះពាល់ចំពោះសន្តិសុខពិភពលោក។<br>**ចរិយាសម្បទា**<br>- ចូលរួមទប់ស្កាត់ការប្រើអំពើហិង្សា និងកម្លាំងយោធាដែលបង្កអសន្តិសុខដល់សង្គម។ | ៤ ម៉ | ៨ ម៉ |
| **មេរៀនទី២ : សង្គ្រាមលោកលើកទី១ និងផលវិបាក**<br>**សិក្សាបញ្ញត្តិ :** លេសសង្គ្រាម ការពង្រីកអំណាច បរាជ័យរបស់អាល្លឺម៉ង់ ផលវិបាកសង្គ្រាម<br>**មាតិកា :**<br>២.១- បុព្វហេតុនៃសង្គ្រាម<br>សំណួរត្រិះរិះ :<br>• តើអ្វីជាបុព្វហេតុនៃសង្គ្រាមលោកលើកទី១?<br>២.២- ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមលោកលើកទី១ប្រព្រឹត្តទៅប៉ុន្មានដំណាក់កាល និងប្រព្រឹត្តទៅយ៉ាងដូចម្ដេច?<br>២.៣- ការបញ្ចប់សង្គ្រាម<br>សំណួរត្រិះរិះ :<br>• តើអាល្លឺម៉ង់ពិតជាបញ្ចប់សង្គ្រាមដោយសារយុទ្ធ | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីបុព្វហេតុនៃសង្គ្រាម ព្រឹត្តការណ៍ សង្គ្រាម និងប្រទេសចូលរួម។<br>**បំណិនសម្បទា**<br>- វិភាគពីការបញ្ចប់សង្គ្រាមលោកលើកទី១ និងការបរាជ័យរបស់អាល្លឺម៉ង់<br>- វិភាគពីផលវិបាកនៃសង្គ្រាម និងផលប៉ះពាល់ខាងនយោបាយ សេដ្ឋកិច្ច និងសង្គមលើទ្វីបអឺរ៉ុប និងពិភពលោក។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីទំហំនៃការបាត់បង់ | ៤ ម៉ | ៨ ម៉ |

| | | | |
|---|---|---|---|
| សន្តិភាពនៅពិតុងមែនឬ?<br>២.៤- ផលវិបាកនៃសង្គ្រាម<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមលោកលើកទី១បង្កផលប៉ះពាល់អ្វីខ្លះដល់នយោបាយ សេដ្ឋកិច្ច និងសង្គមនៃប្រទេសចូលរួមក្នុងសង្គ្រាម និងពិភពលោកទាំងមូល? | និងឥទ្ធិពលអាក្រក់នៃសង្គ្រាមទៅលើសង្គម និងជីវិតមនុស្ស<br>- វិនិច្ឆ័យពីតម្លៃនៃវប្បធម៌សន្ទនា និងចែករំលែក។ | | |
| **មេរៀនទី៣ : សន្ធិសញ្ញាទីក្រុងវ៉ែសៃ និងអត្ថន័យចំពោះអាល្លឺម៉ង់**<br>**សិក្សាបញ្ញត្តិ** : សន្ធិសញ្ញាទីក្រុងវ៉ែសៃ អាល្លឺម៉ង់ សង្គ្រាម<br>**មាតិកា :**<br>៣.១- សន្ធិសញ្ញាទីក្រុងវ៉ែសៃ និងខ្លឹមសារសំខាន់ៗ<br>សំណួរត្រិះរិះ ៖<br>• តើខ្លឹមសារនៃសន្ធិសញ្ញាទីក្រុងវ៉ែសៃមានសារៈសំខាន់យ៉ាងដូចម្ដេចខ្លះ?<br>៣.២- សន្ធិសញ្ញាទីក្រុងវ៉ែសៃ និងអាល្លឺម៉ង់<br>សំណួរត្រិះរិះ ៖<br>• តើសន្ធិសញ្ញាទីក្រុងវ៉ែសៃមានអត្ថន័យយ៉ាងដូចម្ដេចខ្លះចំពោះអាល្លឺម៉ង់? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីខ្លឹមសារសំខាន់ៗនៃសន្ធិសញ្ញាទីក្រុងវ៉ែសៃ។<br>**បំណិនសម្បទា**<br>- វាយតម្លៃពីសន្ធិសញ្ញាក្រុងវ៉ែសៃចំពោះអាល្លឺម៉ង់។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីទំហំនៃការបាត់បង់ និងឥទ្ធិពលអាក្រក់នៃសង្គ្រាមទៅលើសង្គម និងមនុស្ស<br>- វិនិច្ឆ័យពីតម្លៃនៃវប្បធម៌សន្ទនា និងចែករំលែក។ | ៣ ម៉ | ៦ ម៉ |
| **មេរៀនទី៤ : សង្គមប្រជាជាតិ និងបរាជ័យ**<br>**សិក្សាបញ្ញត្តិ** : សង្គមប្រជាជាតិ សន្តិសុខ ពិភពលោក<br>**មាតិកា :**<br>៤.១- មូលហេតុ និងកំណើតសង្គមប្រជាជាតិ<br>**សំណួរត្រិះរិះ :**<br>• តើមូលហេតុអ្វីខ្លះដែលបណ្ដាលឱ្យមានការបង្កើតសង្គមប្រជាជាតិ?<br>៤.២- មូលហេតុ និងបរាជ័យនៃសង្គមប្រជាជាតិ<br>**សំណួរត្រិះរិះ :**<br>• តើមូលហេតុអ្វីខ្លះដែលបណ្ដាលឱ្យសង្គមប្រជាជាតិទទួលបរាជ័យក្នុងបេសកកម្មរបស់ខ្លួន? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីការរៀបចំ និងដំណើរប្រព្រឹត្តទៅរបស់សង្គមប្រជាជាតិ<br>**បំណិនសម្បទា**<br>- វិភាគពីមូលហេតុដែលនាំឱ្យសង្គមប្រជាជាតិទទួលបរាជ័យក្នុងបេសកកម្មរបស់ខ្លួន។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីសារៈសំខាន់ក្នុងការគោរពច្បាប់និងកិច្ចព្រមព្រៀងអន្តរជាតិក្នុងការរក្សាសន្តិភាព។ | ៤ ម៉ | ៨ ម៉ |

## ៧.២- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១១

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង | |
|---|---|---|---|
| | | ទិ.ស | ទិ.សស |
| **ជំពូកទី១ : ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទតំបន់ និងពិភពលោក** | | | |
| **មេរៀនទី ១ : ចតុមុខ និងរាជធានីថ្មី**<br>**សិក្សាបញ្ញត្តិ** : ផលប៉ះពាល់ អន្តរកម្ម ទំនាក់ទំនង រាជធានី អន្តរាគមន៍ ឥទ្ធិពល អយុធ្យា ពាណិជ្ជកម្ម<br>**មាតិកា :**<br>១.១- ការផ្លាស់ប្តូររាជធានី (ទួលបាសាន ចតុមុខ កំពង់សៀម បន្ទាយព្រៃនគរ ពោធិ៍សាត់ បរិបូរណ៍)<br>ក. អត្ថិភាពរាជធានី<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាក្នុងសម័យចតុមុខមានរាជធានីច្រើនកន្លែង?<br>ខ. ចតុមុខ និងរាជធានីសំខាន់ៗ<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាព្រះមហាក្សត្រខ្មែរប្តូររាជធានីពីអង្គរមកទួលបាសាន និងពីទួលបាសានមកចតុមុខ?<br>១.២- កម្ពុជាក្នុងបរិបទតំបន់ និងពិភពលោក<br>ក. នយោបាយ និងពាណិជ្ជកម្មចិន<br>ខ. ការប្រកួតប្រជែងពាណិជ្ជកម្មនៅអាស៊ីអាគ្នេយ៍<br>គ. ឥទ្ធិពលលើកម្ពុជា<br>• នយោបាយ<br>• ពាណិជ្ជកម្ម<br>សំណួរត្រិះរិះ :<br>• តើនយោបាយ និងការផ្លាស់ប្តូរក្នុងតំបន់ និងពិភពលោកជះឥទ្ធិពលយ៉ាងដូចម្តេចលើកម្ពុជា?<br>• តើនយោបាយ និងការផ្លាស់ប្តូររបស់កម្ពុជាជះឥទ្ធិពលអ្វីខ្លះលើប្រទេសជិតខាង និងពិភពលោក?<br>១.៣- អយុធ្យា និងខ្មែរ<br>ក. ដើមកំណើតអយុធ្យា | **វិជ្ជាសម្បទា**<br>- ពន្យល់ពីមូលហេតុនៃអត្ថិភាពនៃរាជធានីជាច្រើនសម័យចតុមុខ។<br>**បំណិនសម្បទា**<br>- វិភាគឥទ្ធិពលនៃនយោបាយ និងពាណិជ្ជកម្មចិន ការមកដល់របស់អឺរ៉ុប និងការរីកចម្រើនរបស់ម៉ាឡាកាលើសេដ្ឋកិច្ច វប្បធម៌ និងនយោបាយកម្ពុជា<br>- វិភាគអន្តរាគមន៍របស់អយុធ្យាក្នុងជម្លោះផ្ទៃក្នុងកម្ពុជា។<br>**ចរិយាសម្បទា**<br>- ស្វែងជម្រើសនៃការសម្រេចចិត្តក្នុងការដោះស្រាយជម្លោះដែលមានហេតុផល។ | ៦ ម៉ | ១២ ម៉ |

| | | | |
|---|---|---|---|
| • ទម្រង់គ្រប់គ្រងរដ្ឋ<br>• ជនជាតិដើម<br>សំណួរត្រិះរិះ :<br>• ហេតុអ្វីបានជាអយុធ្យាចូលអន្តរាគមន៍ក្នុងជម្លោះផ្ទៃក្នុងរបស់ខ្មែរ?<br>ខ. វិបត្តិផ្ទៃក្នុង និងអន្តរាគមន៍ពីខាងក្រៅ<br>• រាជ្យសម្បត្តិ និងការដណ្ដើមអំណាច<br>• អ្នកដឹកនាំ និងកង្វះការលះបង់<br>• ទម្លាប់បន្តសន្តតិវង្ស<br>សំណួរត្រិះរិះ :<br>• តើអយុធ្យាធ្វើអន្តរាគមន៍ក្នុងបញ្ហាផ្ទៃក្នុងខ្មែរបានយ៉ាងដូចម្ដេច?<br>គ. អន្តរាគមន៍អយុធ្យា និងផលវិបាក<br>សំណួរត្រិះរិះ :<br>• តើអន្តរាគមន៍របស់អយុធ្យាផ្ដល់ផលវិបាកអ្វីខ្លះដល់កម្ពុជា?<br>១.៤- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើការសម្រេចចិត្តរបស់ព្រះមហាក្សត្រខ្មែរក្នុងដំណាក់កាលនីមួយៗបានផ្ដល់មេរៀនអ្វីខ្លះសម្រាប់មនុស្សជំនាន់ក្រោយ?<br>• ប្រសិនបើប្អូនជាព្រះមហាក្សត្រខ្មែរ តើចំណុចអ្វីខ្លះដែលប្អូនគួរ និងមិនគួរធ្វើដើម្បីរក្សាសន្តិភាព និងការអភិវឌ្ឍចីរភាពរបស់កម្ពុជា? | | | |
| **មេរៀនទី ២ : លង្វែក និងអំណាចសៀម**<br>**សិក្សាបញ្ញត្តិ** : អន្តរទំនាក់ទំនង ផលប្រយោជន៍ផ្ទាល់ខ្លួន ហេតុផល ភស្តុតាង សាមគ្គីភាព អំណោះអំណាង<br>**មាតិកា** :<br>២.១- បម្រែបម្រួលក្រៅប្រទេស និងឥទ្ធិពលលើលង្វែក<br>ក. លង្វែក និងអឺរ៉ុប<br>ខ. លង្វែក និងដាយវៀត-លាវ<br>គ. លង្វែក និងសៀម<br>• អយុធ្យា និងលង្វែកក្នុងរាជ្យព្រះបាទចន្ទរាជា<br>• អយុធ្យា និងលង្វែកក្នុងរាជ្យព្រះបាទបរមិន្ទរាជា | **វិជ្ជាសម្បទា**<br>- បង្ហាញពីផលវិបាកនៃអន្តរទំនាក់ទំនងរវាងខ្មែរ និងបរទេស។<br>**បំណិនសម្បទា**<br>- ប្រៀបធៀបពីផលប៉ះពាល់នៃការប្រែប្រួលសេដ្ឋកិច្ច និនយោបាយរបស់សៀមលើខ្មែរក្នុងរាជ្យព្រះបាទចន្ទរាជា បរមិន្ទរាជា និងព្រះបាទសត្ថាទី១<br>- វិភាគពីសារៈសំខាន់នៃសាមគ្គី | ៧ ម៉ | ១៤ ម៉ |

| | | | |
|---|---|---|---|
| • អយុធ្យា និងលង្វែកក្នុងរាជ្យព្រះបាទសត្ថាទី១<br>សំណួរត្រិះរិះ :<br>• តើបម្រែបម្រួលនយោបាយ និងសេដ្ឋកិច្ចក្រៅប្រទេសបានផ្តល់ឥទ្ធិពល និងផលវិបាកអ្វីខ្លះដល់កម្ពុជា?<br>២.២- សាមគ្គីភាព និងវិបុលភាព<br>សំណួរត្រិះរិះ :<br>• តើអន្តរទំនាក់ទំនងវិជ្ជមាន និងអវិជ្ជមានរវាងភូមា-សៀម-ខ្មែរ-លាវ ផ្តល់មេរៀនជាបទពិសោធន៍អ្វីខ្លះដល់មនុស្សជំនាន់ក្រោយ?<br>២.៣- កំណត់ត្រាប្រវត្តិសាស្ត្រ និងហេតុផល<br>ក. ការបែកបន្ទាយលង្វែកតាមកំណត់ត្រាសៀម<br>ខ. ការបែកបន្ទាយលង្វែកតាមពង្សាវតារ<br>គ. ការបែកបន្ទាយលង្វែកតាមកំណត់ត្រាអឺរ៉ុប<br>សំណួរត្រិះរិះ :<br>• តើមានការពន្យល់បែបណាខ្លះពីមូលហេតុនៃការបែកបន្ទាយលង្វែក? | ភាពរវាងប្រទេសក្នុងតំបន់។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានអំពីព្រឹត្តការណ៍ប្រវត្តិសាស្ត្រដោយប្រើភស្តុតាង។ | | |
| **មេរៀនទី ៣ : ឧដុង្គ និងការប្រជែងអំណាចរវាងសៀមនិងយួន**<br>**សិក្សាបញ្ញត្តិ** : ឥទ្ធិពល អនិស្សរភាព បូរណភាព ការរាតទីអំណាច ទឹកឡើងត្រីស៊ីស្រមោច ទឹកហោចស្រមោចស៊ីត្រី<br>**មាតិកា :**<br>៣.១- ការមកដល់របស់អឺរ៉ុប និងឥទ្ធិពលលើកម្ពុជា<br>សំណួរត្រិះរិះ :<br>• តើការមកដល់របស់អឺរ៉ុបបានធ្វើឱ្យនយោបាយពាណិជ្ជកម្ម សេដ្ឋកិច្ច ការអប់រំ និងសាសនា ក្នុងសង្គមខ្មែរប្រែប្រួលយ៉ាងដូចម្តេចខ្លះ?<br>៣.២- ចំណងការទូត និងពាណិជ្ជកម្មរបស់កម្ពុជា<br>សំណួរត្រិះរិះ :<br>• តើខ្មែរមានចំណងការទូត និងពាណិជ្ជកម្មជាមួយប្រទេសណាខ្លះ? តើចំណងនេះបានផ្តល់ប្រយោជន៍អ្វីខ្លះដល់កម្ពុជា?<br>៣.៣- សៀម-យួន និងការប្រជែងអំណាចលើកម្ពុជា<br>សំណួរត្រិះរិះ : | **វិជ្ជាសម្បទា**<br>- រៀបរាប់អំពីឥទ្ធិពលនៃការមកដល់របស់ពួកអឺរ៉ុបលនយោបាយ ពាណិជ្ជកម្ម សេដ្ឋកិច្ច អប់រំ និងសាសនា<br>- រៀបរាប់អំពីចំណងការទូត និងពាណិជ្ជកម្ម ជាមួយបរទេស<br>- រៀបរាប់អំពីអំណាចនយោបាយសៀម និងយួនមកលើសង្គមខ្មែរនៅសម័យឧដុង្គ<br>- រៀបរាប់អំពីការចាប់ផ្តើមទំនាក់ទំនងជាមួយបារាំងរបស់ព្រះបាទអង្គដួងនិងលទ្ធផល។<br>**បំណិនសម្បទា**<br>- វិភាគពីការប្រកួតប្រជែងអំណាចរវាងសៀម និងយួនដើម្បីគ្រប់គ្រងខ្មែរ | ៩ ម៉ | ១៨ ម៉ |

| | | | |
|---|---|---|---|
| • ហេតុអ្វីបានជាសៀម និងយួនប្រជែងអំណាចដើម្បីគ្រប់គ្រងខ្មែរ? តើការប្រកួតប្រជែងអំណាចរវាងសៀម និងយួនបង្កផលវិបាកអ្វីខ្លះដល់កម្ពុជា?<br>៣.៤- មធ្យោបាយចេញពីអំណាចសៀម និងយួន<br>សំណួរត្រិះរិះ :<br>• តើព្រះបាទអង្គដួងបានប្រើមធ្យោបាយអ្វីខ្លះដើម្បីបង្កើតទំនាក់ទំនងជាមួយបារាំង? តើការខិតខំប្រឹងប្រែងរបស់ព្រះបាទអង្គដួងក្នុងការបង្កើតទំនាក់ទំនងជាមួយបារាំងបន្សល់នូវលទ្ធផល និងបទពិសោធអ្វីខ្លះសម្រាប់ខ្មែរ?<br>៣.៥- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើការសម្រេចព្រះទ័យ និងវិធីក្នុងការរើបម្រាសចេញពីសៀម និងយួនរបស់ព្រះបាទអង្គដួងសមស្របនឹងបរិបទក្នុងសម័យកាលនោះដែរឬយ៉ាងណា? ព្រោះហេតុអ្វី? | - វាយតម្លៃលើការសម្រេចចិត្ត និងវិធីរបស់ខ្មែរក្នុងការរើបម្រាសចេញពីសៀម និងយួន។<br>**ចរិយាសម្បទា**<br>- បណ្ដុះទម្លាប់នៃការផ្ដល់តម្លៃចំពោះស្មារតីការយោគយល់ និងសាមគ្គីភាព។ | | |
| **មេរៀនទី ៤ : កម្ពុជា និងអាណាព្យាបាលបារាំង**<br>**សិក្សាបញ្ញត្តិ** : អន្តរទំនាក់ទំនង នយោបាយ ការតស៊ូ ឯករាជ្យ ជាតិនិយម សង្គ្រាម ផលវិជ្ជមាន ផលអវិជ្ជមាន មហាអំណាច អាណានិគម<br>**មាតិកា :**<br>៤.១- មហាអំណាចអឺរ៉ុប និងអធិបតេយ្យភាពកម្ពុជា<br>សំណួរត្រិះរិះ :<br>• តើមហាអំណាចអឺរ៉ុបណាខ្លះដែលបានចូលមកទាញផលប្រយោជន៍ ឬដាក់អាណានិគមក្នុងតំបន់អាស៊ីអាគ្នេយ៍?<br>• ហេតុអ្វីបានជាប្រទេសអឺរ៉ុបទាំងនោះមិនផ្ដោតការដាក់អាណានិគមលើកម្ពុជា?<br>៤.២- កម្ពុជា និងសង្គ្រាមលោកលើកទី១<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមលោកលើកទី១ បានធ្វើឱ្យបារាំងផ្លាស់ប្ដូរការសម្រេចចិត្តនយោបាយយ៉ាងដូចម្ដេចខ្លះចំពោះកម្ពុជា?<br>៤.៣- កម្ពុជា និងសង្គ្រាមលោកលើកទី២ | **វិជ្ជាសម្បទា**<br>- ពន្យល់ពីនិន្នាការ និងចំណាប់អារម្មណ៍របស់មហាអំណាចអឺរ៉ុបផ្សេងទៀត ក្រៅពីបារាំង ក្នុងការដាក់អាណានិគមលើខ្មែរ<br>- រៀបរាប់ផលប៉ះពាល់នៃសង្គ្រាមលោកលើកទី១ លើសង្គម និងសេដ្ឋកិច្ចកម្ពុជា។<br>**បំណិនសម្បទា**<br>- វិភាគឥទ្ធិពលនៃសង្គ្រាមលោកលើកទី២ លើស្ថានភាពសង្គម នយោបាយ និង សេដ្ឋកិច្ចកម្ពុជា<br>- ចង្អុលបង្ហាញឥទ្ធិពលនៃនយោបាយជាតិនិយមលើកម្ពុជា<br>- វិភាគពីឥទ្ធិពលកុសាំងស៊ីនលើកម្ពុជា<br>- វិភាគពីឥទ្ធិពលនយោបាយតំបន់ និងពិភពលោកក្នុងការជំរុញកម្ពុ | ១៣ម៉ | ២៦ ម៉ |

| | | | |
|---|---|---|---|
| ក. ឥទ្ធិពលជប៉ុនលើកម្ពុជា<br>សំណួរគ្រិះ :<br>• ជប៉ុនមានឥទ្ធិពលយ៉ាងដូចម្ដេចខ្លះចំពោះកម្ពុជាក្នុងអំឡុងសង្គ្រាមលោកលើកទី២?<br>ខ. កម្ពុជា និងឯករាជ្យភាព<br>សំណួរគ្រិះ :<br>• តើកម្ពុជាបានទាញផលចំណេញអ្វីខ្លះពីភាពចុះខ្សោយរបស់បារាំងក្នុងអំឡុងសង្គ្រាមលោកលើកទី២?<br>គ. ការវិលត្រឡប់របស់បារាំង និងកំណែទម្រង់<br>សំណួរគ្រិះ :<br>• តើសង្គ្រាមលោកលើកទី២បានធ្វើឱ្យបារាំងផ្លាស់ប្ដូរការសម្រេចចិត្តនយោបាយ និងឥរិយាបថបែបណាខ្លះចំពោះកម្ពុជា?<br>៤.៤- កម្ពុជា និងឥទ្ធិពលជាតិនិយមថៃ<br>ក. បាត់ដំបងក្នុងសម័យសង្គ្រាមលោកលើកទី២<br>ខ. ខ្មែរឥស្សរៈនិយមថៃ<br>សំណួរគ្រិះ :<br>• តើនយោបាយជាតិនិយមរបស់ថៃប៉ះពាល់អ្វីខ្លះចំពោះវប្បធម៌នយោបាយសង្គម និងអធិបតេយ្យភាពកម្ពុជា?<br>៤.៥- អំណាចកូសាំងស៊ីនលើកម្ពុជា<br>ក. ការតែងតាំងមន្ត្រីជាន់ខ្ពស់<br>ខ. ការកំណត់ព្រំដែនរដ្ឋបាល<br>គ. ការកំណត់ដែនពាណិជ្ជកម្ម<br>សំណួរគ្រិះ :<br>• តើនយោបាយកូសាំងស៊ីននាំមកនូវផលប៉ះពាល់អ្វីខ្លះដល់កម្ពុជាក្នុងអំឡុងសម័យអាណាព្យាបាលបារាំង?<br>៤.៦- កម្ពុជា និងឯករាជ្យពេញបរិបូរណ៍<br>ក. ប្រទេសជិតខាង និងចលនាខ្មែរឥស្សរៈ<br>សំណួរគ្រិះ :<br>• តើប្រទេសជិតខាងបានរួមចំណែកយ៉ាងដូចម្ដេចខ្លះក្នុងការបង្កើត និងជំរុញការវិវត្តរបស់ចលនាខ្មែរ | ជាឱ្យទទួលបានឯករាជ្យ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីតម្លៃនៃទំនាក់ទំនងវិជ្ជមានដើម្បីដោះស្រាយបញ្ហា។ | | |

| | | | |
|---|---|---|---|
| ឥស្សរៈ និងខ្មែរវៀតមិញ?<br>ខ. ជំហររបស់ព្រះបាទនរោត្តមសីហនុ និងឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើព្រះបាទនរោត្តមសីហនុ មានជំហរយ៉ាងដូចម្ដេចខ្លះ បានជាបារាំងព្រមប្រគល់ឯករាជ្យឱ្យខ្មែរ?<br>គ. សង្គ្រាមត្រជាក់ និងឯករាជ្យនៅកម្ពុជា<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមត្រជាក់ជះឥទ្ធិពលយ៉ាងដូចម្ដេចខ្លះចំពោះការទាមទារឯករាជ្យនៅកម្ពុជា?<br>ឃ. សន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤<br>សំណួរត្រិះរិះ :<br>• តើសន្និសីទទីក្រុងហ្សឺណែវមានអត្ថន័យយ៉ាងដូចម្ដេចចំពោះឯករាជ្យភាពកម្ពុជា?<br>៤.៧- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តាមរយៈការទាមទារឯករាជ្យតើក្រុមដែលមាននិន្នាការនយោបាយខុសគ្នា គួរបង្កើតនិងរក្សាទំនាក់ទំនងវិជ្ជមានជាមួយគ្នាយ៉ាងដូចម្ដេចខ្លះ ដើម្បីប្រយោជន៍ និងលទ្ធផលវិជ្ជមានសម្រាប់ជាតិ? | | | |
| **ជំពូកទី ២ : ប្រវត្តិសាស្ត្រតំបន់អាស៊ីអាគ្នេយ៍ និងឯករាជ្យ( សតវត្សរ៍ទី២០ )** | | | |
| **មេរៀនទី១ : អាស៊ីអាគ្នេយ៍ និងការបញ្ចប់អាណានិគមរបស់អឺរ៉ុប**<br>**សិក្សាបញ្ញត្តិ :** ការប្រឆាំងអាណានិគមនិយម ការទាមទារឯករាជ្យ ជាតិនិយម រដ្ឋប្រជាជាតិ អធិបតេយ្យភាព ឯករាជ្យ ចលនាប្រឆាំង កិច្ចសហការ<br>**មាតិកា :**<br>១.១- ក្រុមជាតិនិយម និងការប្រឆាំងនឹងពួក អាណានិគម<br>សំណួរត្រិះរិះ :<br>• តើក្រុមជាតិនិយមជាអ្នកណា និងចូលរួមក្នុងការទាមទារឯករាជ្យដោយរបៀបណា?<br>១.២- បម្រែបម្រួលពិភពលោក និងចលនាឯករាជ្យ<br>សំណួរត្រិះរិះ : | **វិជ្ជាសម្បទា**<br>- ប្រាប់ពីបច្ច័យដែលនាំឱ្យមានឯករាជ្យភាពនៅអាស៊ីអាគ្នេយ៍។<br>**បំណិនសម្បទា**<br>- វិភាគពីស្ថានភាពពិភពលោកដែលនាំឱ្យអាស៊ីអាគ្នេយ៍ទទួលបានឯករាជ្យ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីអន្តរទំនាក់ទំនងរវាងប្រជាជន ក្នុងតំបន់ និងលើពិភពលោក។ | ៥ ម៉ | ១០ ម៉ |

| | | | |
|---|---|---|---|
| • តើស្ថានភាពពិភពលោកបានរួមចំណែកក្នុងការបញ្ចប់របបអាណានិគមនិយមយ៉ាងដូចម្ដេច?<br>១.៣-ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• សរសេរអធិប្បាយពីកត្តាដែលជំរុញឱ្យរបបអាណានិគមនិយមឈានដល់ទីបញ្ចប់នៅអាស៊ីអាគ្នេយ៍ | | | |
| **មេរៀនទី ២ : ជ្រោយម៉ាឡាយូ និងឯករាជ្យ**<br>**សិក្សាបញ្ញត្តិ** : ការប្រឆាំងអាណានិគមនិយម ការទាមទារឯករាជ្យ ជាតិនិយម រដ្ឋប្រជាជាតិ អធិបតេយ្យភាព ឯករាជ្យ ចលនាប្រឆាំង កិច្ចសហការ<br>**មាតិកា :**<br>២.១- សង្គ្រាមលោកលើកទី២ និង ការទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមលោកលើកទី២ផ្ដល់ឥទ្ធិពលយ៉ាងដូចម្ដេចខ្លះក្នុងការទាមទារឯករាជ្យ?<br>២.២- អង់គ្លេស និងការតបតចំពោះចលនាទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើអង់គ្លេសមានវិធានការបែបណាខ្លះដើម្បីទប់ស្កាត់ការទាមទារឯករាជ្យ?<br>២.៣-បដិវត្តន៍ និងការទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើជ្រោយម៉ាឡាយូទទួលបានឯករាជ្យពេញបរិបូរណ៍ដោយរបៀបណា?<br>២.៤-ជ្រោយម៉ាឡាយូក្រោយឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើម៉ាឡាយូស្ថិតក្នុងសភាពបែបណាក្នុងអំឡុងសង្គ្រាមត្រជាក់?<br>២.៥- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកត្តាក្នុងប្រទេស និងកត្តាក្រៅប្រទេសមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេចខ្លះក្នុងការទទួលបានឯករាជ្យ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃសង្គ្រាមលោកលើកទី២ចំពោះការទាមទារឯករាជ្យនៅជ្រោយម៉ាឡាយូ<br>- ពន្យល់ពីឥទ្ធិពលនៃសង្គ្រាមត្រជាក់ក្នុងការជំរុញការទាមទារឯករាជ្យនៅជ្រោយម៉ាឡាយូ។<br>**បំណិនសម្បទា**<br>- វិភាគពីការទាមទារឯករាជ្យក្នុងអំឡុងមុន សង្គ្រាមត្រជាក់នៅជ្រោយម៉ាឡាយូ<br>- ចង្អុលបង្ហាញពីគោលនយោបាយដែលអង់គ្លេសបានប្រើប្រាស់ក្នុងការឆ្លើយតបនឹងការទាមទារឯករាជ្យរបស់ជ្រោយម៉ាឡាយូ<br>- ចង្អុលបង្ហាញពីមូលហេតុ និងវិធីសាស្ត្ររបស់ជ្រោយម៉ាឡាយូក្នុងការទាមទារឯករាជ្យបានយ៉ាងជោគជ័យ<br>- សន្និដ្ឋានពីជ្រោយម៉ាឡាយូក្រោយទទួលបានឯករាជ្យ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការសម្រេចចិត្ត និងសកម្មភាពរបស់មនុស្សក្នុងអតីតកាលដើម្បីឆ្លើយតបនឹង | ៥ ម៉ | ១០ ម៉ |

| | | | |
|---|---|---|---|
| | ព្រឹត្តិការណ៍<br>- សន្និដ្ឋានរួមពីអន្តរទំនាក់ទំនងរវាងប្រជាជន ប្រទេស តំបន់ និងពិភពលោក។ | | |
| **មេរៀនទី ៣ : វៀតណាម និងឯករាជ្យ**<br>**សិក្សាបញ្ញត្តិ** : ការប្រឆាំងអាណានិគមនិយម ការទាមទារឯករាជ្យ ជាតិនិយម រដ្ឋប្រជាជាតិ អធិបតេយ្យភាព ឯករាជ្យ ចលនាប្រឆាំង<br>កិច្ចសហការ<br>**មាតិកា :**<br>៣.១- សង្គ្រាមលោកលើកទី២ និង ការទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមលោកលើកទី២ផ្តល់ឥទ្ធិពលយ៉ាងដូចម្តេចខ្លះក្នុងការទាមទារឯករាជ្យ?<br>៣.២- បារាំង និងការតបតចំពោះចលនាទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើបារាំងមានវិធានការបែបណាខ្លះដើម្បីទប់ស្កាត់ការទាមទារឯករាជ្យ?<br>៣.៣- បដិវត្តន៍ និងការទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើវៀតណាមទទួលបានឯករាជ្យពេញបរិបូរណ៍ដោយរបៀបណា?<br>៣.៤- វៀតណាមក្រោយឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើវៀតណាមស្ថិតក្នុងសភាពបែបណាក្នុងអំឡុងសង្គ្រាមត្រជាក់?<br>៣.៥- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកត្តាក្នុងប្រទេស និងកត្តាក្រៅប្រទេសមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះក្នុងការទទួលបានឯករាជ្យ? | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃសង្គ្រាមលោកលើកទីពីរចំពោះការទាមទារឯករាជ្យនៅវៀតណាម<br>- ពន្យល់ពីឥទ្ធិពលនៃសង្គ្រាមត្រជាក់ក្នុងការជំរុញការទាមទារឯករាជ្យនៅវៀតណាម។<br>**បំណិនសម្បទា**<br>- វិភាគពីការទាមទារឯករាជ្យក្នុងអំឡុងមុនសង្គ្រាមត្រជាក់នៅវៀតណាម<br>- វិភាគពីការសម្រេចចិត្តរបស់បារាំងក្នុងការឆ្លើយតបនឹងការទាមទារឯករាជ្យរបស់វៀតណាម<br>- ឆ្លុះបញ្ចាំងភាពពាក់ព័ន្ធនៃការសម្រេចចិត្តរបស់វៀតណាមក្នុងការទាមទារឯករាជ្យ<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីការសម្រេចចិត្ត និងសកម្មភាពរបស់មនុស្សក្នុងអតីតកាលដើម្បីឆ្លើយតបនឹងព្រឹត្តិការណ៍<br>- សន្និដ្ឋានរួមពីអន្តរទំនាក់ទំនងរវាងប្រជាជន ប្រទេស តំបន់ និងពិភពលោក។ | ៥ ម៉ | ១០ ម៉ |
| **មេរៀនទី ៤ : ឥណ្ឌូណេស៊ី និងឯករាជ្យ**<br>**សិក្សាបញ្ញត្តិ** : ការប្រឆាំងអាណានិគមនិយម ការទាមទារ | **វិជ្ជាសម្បទា**<br>- ប្រាប់ពីឥទ្ធិពលនៃសង្គ្រាមលោក | ៥ ម៉ | ១០ ម៉ |

| | | | |
|---|---|---|---|
| ឯករាជ្យ ជាតិនិយម រដ្ឋប្រជាជាតិ អធិបតេយ្យភាព ឯករាជ្យ ចលនាប្រឆាំង កិច្ចសហការ<br>**មាតិកា :**<br>៤.១- សង្គ្រាមលោកលើកទី២ និងការទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើសង្គ្រាមលោកលើកទី២ផ្តល់ឥទ្ធិពលយ៉ាងដូចម្តេចខ្លះក្នុងការទាមទារឯករាជ្យ?<br>៤.២- ហូឡង់ និងការតបតចំពោះចលនាទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើហូឡង់មានវិធានការបែបណាខ្លះដើម្បីទប់ស្កាត់ការទាមទារឯករាជ្យ?<br>៤.៣- បដិវត្តន៍ និងការទាមទារឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើឥណ្ឌូណេស៊ីទទួលបានឯករាជ្យពេញបរិបូរណ៍ដោយរបៀបណា?<br>៤.៤- ឥណ្ឌូណេស៊ីក្រោយឯករាជ្យ<br>សំណួរត្រិះរិះ :<br>• តើឥណ្ឌូណេស៊ីស្ថិតក្នុងស្ថានភាពដូចម្តេច ក្នុងអំឡុងសង្គ្រាមត្រជាក់?<br>៤.៥- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តើកត្តាក្នុងប្រទេស និងក្រៅប្រទេសមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចខ្លះក្នុងការទទួលបានឯករាជ្យ? | លើកទី២ចំពោះការទាមទារឯករាជ្យនៅឥណ្ឌូណេស៊ី<br>- ពន្យល់ពីឥទ្ធិពលនៃសង្គ្រាមត្រជាក់ក្នុងការជំរុញការទាមទារឯករាជ្យនៅឥណ្ឌូណេស៊ី។<br>**បំណិនសម្បទា**<br>- វិភាគពីការទាមទារឯករាជ្យក្នុងអំឡុងមុនសង្គ្រាមត្រជាក់នៅឥណ្ឌូណេស៊ី<br>- វិភាគពីការសម្រេចចិត្តរបស់ហូឡង់ក្នុងការឆ្លើយតបនឹងការទាមទារឯករាជ្យរបស់ឥណ្ឌូណេស៊ី<br>- ចង្អុលបង្ហាញពីមូលហេតុ និងវិធីសាស្ត្ររបស់ឥណ្ឌូណេស៊ីក្នុងការទាមទារឯករាជ្យបានយ៉ាងជោគជ័យ<br>- សន្និដ្ឋានពីឥណ្ឌូណេស៊ីក្រោយទទួលបានឯករាជ្យ។<br>**ចរិយាសម្បទា**<br>- ទទួលស្គាល់ប្រកបដោយសុភវិនិច្ឆ័យនូវការសម្រេចចិត្ត និងសកម្មភាពរបស់មនុស្សក្នុងអតីតកាលថាកើតឡើង ឬប្រព្រឹត្តទៅតាមបរិបទក្នុងសម័យនោះ<br>- សន្និដ្ឋានរួមប្រកបដោយគតិបណ្ឌិតស្តីពីអន្តរទំនាក់ទំនងរវាងប្រជាជន ប្រទេស តំបន់ និងពិភពលោក។ | | |

| ជំពូកទី៣ : ប្រវត្តិសាស្ត្រពិភពលោក "សង្គ្រាមលោកលើកទី២ និងការបែងចែកពិភពលោក (១៩៣៩-១៩៤៥)" | | | |
|---|---|---|---|
| **មេរៀនទី១ : ពិភពលោក និងវិបត្តិនៅចន្លោះសង្គ្រាមលោកទាំងពីរ** | **វិជ្ជាសម្បទា**<br>- ប្រាប់ពីមូលហេតុនៃការផ្ទុះវិបត្តិ | ៤ ម៉ | ៨ ម៉ |

| | | | |
|---|---|---|---|
| **សិក្សាបញ្ញត្តិ :** វិបត្តិសេដ្ឋកិច្ច វិបត្តិហិរញ្ញវត្ថុ វិបត្តិនយោបាយ វិបត្តិសង្គម របបផ្តាច់ការ ហ្វាស៊ីស ណាស៊ីយោធានិយម ញូវឌាល<br>**មាតិកា :**<br>១.១- ការផ្ទុះវិបត្តិក្រោយសង្គ្រាមលោកលើកទី១<br>ក. វិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ខ. វិបត្តិនយោបាយ<br>គ. វិបត្តិសង្គម<br>សំណួរគ្រឹះ :<br>• តើនៅក្រោយសង្គ្រាមលោកលើកទី១ ប្រទេសនានានៅអឺរ៉ុបជួបវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ នយោបាយ និងសង្គមយ៉ាង ដូចម្តេចខ្លះ ?<br>១.២- ដំណោះ ស្រាយវិបត្តិ<br>ក. សេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ខ. នយោបាយ និងសង្គម<br>សំណួរគ្រឹះ :<br>• តើរដ្ឋាភិបាលនៃប្រទេសនានានៅអឺរ៉ុប និងសហរដ្ឋអាមេរិកដោះស្រាយវិបត្តិសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសង្គមយ៉ាងដូចម្តេច ?<br>១.៣- មហាអំណាចមុនសង្គ្រាមលោកលើកទី២ និងមហិច្ឆិតា<br>ក. មហាអំណាចនៅអឺរ៉ុប<br>ខ. មហាអំណាចនៅអាស៊ី<br>គ. មហាអំណាចនៅអាមេរិក<br>សំណួរគ្រឹះ :<br>• តើប្រទេសមហាអំណាច មុនសង្គ្រាមលោកលើកទី២ បានប្រកាន់យករបប នយោបាយបែបណា? | ក្រោយសង្គ្រាមលោកលើកទី១ នៅប្រទេសបារាំង អង់គ្លេស អាល្លឺម៉ង់ និងអាមេរិក<br>- ប្រាប់ពីស្ថានភាពនយោបាយ សេដ្ឋកិច្ចយោធារបស់មហាអំណាចមុនសង្គ្រាមលោកលើកទី២។<br>**បំណិនសម្បទា**<br>- វិភាគពីការសម្រេចចិត្ត និងវិធានការរបស់រដ្ឋាភិបាលពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហា<br>- វិភាគពីមូលហេតុនៃការលេចឡើងនូវសង្គមនិយម លទ្ធិផ្តាច់ការ របបយោធានិយមនៅលើពិភពលោក។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានរួមពីរបៀបគ្រប់គ្រងរដ្ឋ និងការដោះស្រាយបញ្ហាដោយសន្តិវិធី។ | | |
| **មេរៀនទី២ : សង្គ្រាមលោកលើកទី២ និងផលវិបាក**<br>**សិក្សាបញ្ញត្តិ :** បញ្ហាអាល្លឺម៉ង់ អឺរ៉ុបកណ្តាល បាល់កង់ មជ្ឈិមបូព៌ា រ៉ូម បែរឡាំង តូក្យូ សម្ព័ន្ធមិត្ត បរមាណូ<br>**មាតិកា :**<br>២.១-បញ្ហាសំខាន់ៗមុនសង្គ្រាមលោកលើកទី២<br>ក. បញ្ហាអាល្លឺម៉ង់<br>ខ. អឺរ៉ុបកណ្តាល | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីបញ្ហាកើតឡើងនៅមជ្ឈិមបូព៌ា និងនៅចុងបូព៌ា<br>- ប្រាប់ពីបុព្វហេតុនៃការផ្ទុះសង្គ្រាម និងដំណើរប្រព្រឹត្តទៅនៃសង្គ្រាមលោកលើកទី២<br>**បំណិនសម្បទា** | ៤ ម៉ | ៨ ម៉ |

| | | | |
|---|---|---|---|
| គ. តំបន់បាល់កង់<br>ឃ. មជ្ឈិមបូព៌ា<br>ង. ចុងបូព៌ា<br>ច. ល្បិចកលមហាអំណាចមុនផ្ទុះសង្គ្រាម<br>សំណួរគន្លឹះ :<br>• តើប្រទេសអាល្លឺម៉ង់អនុវត្តនយោបាយបែបណាដើម្បីត្រួតត្រាពិភពលោក ?<br>• តើការប៉ះទង្គិចគ្នារវាងមហាអំណាចក្នុងការដណ្ដើមឥទ្ធិពលគ្នានៅអឺរ៉ុប និងតំបន់បាល់កង់ផ្ដល់នូវផលវិបាកដូចម្ដេច ?<br>• ចូរបង្ហាញពីឧបាយកលរបស់មហាអំណាច និងផលប៉ះពាល់<br>២.២- បុព្វហេតុនៃសង្គ្រាម<br>សំណួរគន្លឹះ :<br>• អ្វីជាបុព្វហេតុនាំឱ្យផ្ទុះសង្គ្រាមលោកលើកទី២?<br>២.៣- ដំណើរប្រព្រឹត្តទៅនៃសង្គ្រាម<br>ក. អាល្លឺម៉ង់ និងសង្គ្រាមលោកលើកទី២<br>ខ. ជប៉ុន និងសង្គ្រាមលោកលើកទី២<br>សំណួរគន្លឹះ :<br>• តើសង្គ្រាមលោកលើកទី២ប្រព្រឹត្តទៅយ៉ាងដូចម្ដេច?<br>• តើប្រទេសណាខ្លះដែលបានប្រឡូកចូលក្នុងសង្គ្រាម?<br>២.៤- ការបញ្ចប់សង្គ្រាម និងផលវិបាក<br>សំណួរគន្លឹះ :<br>• តើសង្គ្រាមលោកលើកទី២បញ្ចប់ទៅដូចម្ដេច?<br>• តើជប៉ុនពិតជាចុះចាញ់សង្គ្រាមដោយសារការទម្លាក់គ្រាប់បែកបរមាណូនៅជប៉ុនមែនឬ?<br>• តើសង្គ្រាមលោកលើកទី២ផ្ដល់ផលវិបាកយ៉ាងដូចម្ដេច ? | - វិភាគល្បិចកលរបស់មហាអំណាចមុនសង្គ្រាមលោកលើកទី២ និងផលប៉ះពាល់<br>- វិភាគពីមូលហេតុនៃការប៉ះទង្គិចគ្នារបស់មហាអំណាចដើម្បីដណ្ដើមឥទ្ធិពលនៅអឺរ៉ុបកណ្ដាល និងឧបទ្វីបបាល់កង់<br>- វិភាគពីផលប៉ះពាល់នៃសង្គ្រាមចំពោះសង្គម សេដ្ឋកិច្ច និងនយោបាយ។<br>**ចរិយាសម្បទា**<br>- សន្និដ្ឋានពីសារៈសំខាន់នៃការចូលរួមទប់ស្កាត់អំពើហិង្សា<br>- សន្និដ្ឋានរួមពីទំហំនៃការបាត់បង់ និងឥទ្ធិពលអាក្រក់នៃសង្គ្រាមទៅលើសង្គម នយោបាយ សេដ្ឋកិច្ច និងជីវិតមនុស្ស។ | | |
| **មេរៀនទី៣ : អង្គការសហប្រជាជាតិ និងទិសដៅសន្តិភាព**<br>**សិក្សាបញ្ញត្តិ :** ទិសដៅ គោលការណ៍ សន្តិសុខសន្តិភាព ភាពរុងរឿង ការអភិវឌ្ឍ យុត្តិធម៌<br>**មាតិកា** | **វិជ្ជាសម្បទា**<br>- បង្ហាញពីហេតុផលនានា ទិសដៅ និងគោលការណ៍នៃការបង្កើតអង្គការសហប្រជាជាតិ | ៤ ម៉ | ៨ ម៉ |

| | | | |
|---|---|---|---|
| ៣.១- បុព្វហេតុ និងដំណើរនៃការបង្កើតអង្គការ សហប្រជាជាតិ<br>សំណួរត្រិះរិះ :<br>• តើមានបុព្វហេតុណាខ្លះដែលនាំទៅរកការបង្កើតអង្គការសហប្រជាជាតិ?<br>• តើអង្គការសហប្រជាជាតិបង្កើតឡើងយ៉ាងដូចម្ដេច?<br>៣.២- ទិសដៅ និងគោលការណ៍អង្គការសហប្រជាជាតិ<br>សំណួរត្រិះរិះ :<br>• តើអង្គការសហប្រជាជាតិមានទិសដៅសំខាន់អ្វីខ្លះ?<br>• តើអង្គការសហប្រជាជាតិមានគោលការណ៍យ៉ាងដូចម្ដេចខ្លះ ?<br>៣.៣-ស្ថាប័ននានារបស់អង្គការសហប្រជាជាតិ<br>សំណួរត្រិះរិះ :<br>• តើអង្គការសហប្រជាជាតិមានស្ថាប័នអ្វីខ្លះ ?<br>• តើស្ថាប័ននីមួយៗមានតួនាទីដូចម្ដេចខ្លះ ?<br>៣.៤- ការវិវត្តនៃអង្គការសហប្រជាជាតិ<br>• អង្គការសហប្រជាជាតិក្នុងសម័យសង្គ្រាមត្រជាក់<br>• អង្គការសហប្រជាជាតិក្រោយសម័យសង្គ្រាមត្រជាក់<br>សំណួរត្រិះរិះ :<br>• ចូរធ្វើការប្រៀបធៀបពីប្រសិទ្ធភាពការងារ ក្នុងនិងក្រោយសម័យសង្គ្រាមត្រជាក់របស់អង្គការសហប្រជាជាតិ ? | - ប្រាប់ពីលក្ខខណ្ឌនានា និងស្ថាប័ននានារបស់អង្គការសហប្រជាជាតិដែលមានចែងក្នុងមាត្រា១ និងមាត្រា២ នៃធម្មនុញ្ញ។<br>**បំណិនសម្បទា**<br>- វិភាគពីតួនាទី និងបេសកកម្មរបស់អង្គការសហប្រជាជាតិក្រោយសង្គ្រាមត្រជាក់។<br>**ចរិយាសម្បទា**<br>- ចូលរួមដោះស្រាយបញ្ហាក្នុងសហគមន៍យើងរស់នៅដោយសន្តិភាព<br>- ចូលរួមគោរពសិទ្ធិរស់រានមានជីវិត និងគោរពច្បាប់ជាតិ និងអន្តរជាតិ | | |
| **មេរៀនទី៤ : មជ្ឈិមបូព៌ា និងបញ្ហាជាតិសាសន៍**<br>**សិក្សាបញ្ញត្តិ :** ចម្រុះជាតិសាសន៍ សាសនា ឥស្លាម អ៊ីស្រាអែល សាសនាគ្រិស្ត ធនធានប្រេង ទន្លេនីល<br>**មាតិកា :**<br>៤.១- សាសនា និងជាតិសាសន៍នៅមជ្ឈិមបូព៌ា<br>សំណួរត្រិះរិះ :<br>• តើអ្វីជាបញ្ហាសំខាន់នៅមជ្ឈិមបូព៌ា? ចូរបង្ហាញពីមូលហេតុនៃបញ្ហាទាំងនោះ?<br>• ហេតុអ្វីបានជាមជ្ឈិមបូព៌ាក្លាយជាតំបន់ប្រកាន់សាសនាឥស្លាម? | **វិជ្ជាសម្បទា**<br>- រៀបរាប់ពីស្ថានភាពសង្គម ប្រទេស ប្រជាជន និងសាសនានៅមជ្ឈិមបូព៌ា<br>- រៀបរាប់ពីជីវភាពរបស់ប្រជាជននៅមជ្ឈិមបូព៌ាក្នុងសម័យសង្គ្រាមលោកលើកទី១និងទី២។<br>**បំណិនសម្បទា**<br>- វិភាគមូលហេតុជម្លោះមជ្ឈិមបូព៌ា<br>- សន្និដ្ឋានពីគោលបំណងរបស់ | ៣ ម៉ | ៦ ម៉ |

| | | | |
|---|---|---|---|
| • តើមានមហាអំណាចណាខ្លះដែលលូកដៃចូលក្នុងរឿងនៅមជ្ឈិមបូព៌ា ?<br>• តើស្ត្រីនៅមជ្ឈិមបូព៌ាទទួលបានសិទ្ធិយ៉ាងដូចម្តេច?<br>៤.២- ឥទ្ធិពលសង្គ្រាមលោក និងការបង្កើតរដ្ឋមជ្ឈិមបូព៌ា<br>សំណួរត្រិះរិះ :<br>• តើរដ្ឋនៅមជ្ឈិមបូព៌ាកើតឡើងយ៉ាងដូចម្តេច ?<br>• តើរដ្ឋទាំងនោះដណ្តើមឧត្តមភាពគ្នាយ៉ាងដូចម្តេច ? | មហាអំណាចមកលើប្រទេសនៅមជ្ឈិមបូព៌ា<br>- វិភាគពីតួនាទី និងសិទ្ធិរបស់ស្ត្រីនៅក្នុងសង្គមមជ្ឈិមបូព៌ា។<br>**ចរិយាសម្បទា**<br>- វាយតម្លៃពីការចូលរួមលើកតម្កើងសិទ្ធិស្ត្រី និងមិនប្រកាន់ពូជសាសន៍ និងសាសនាដទៃ។ | | |

### ៧.៣- កម្មវិធីសិក្សាលម្អិតថ្នាក់ទី១២

| ខ្លឹមសារ | លទ្ធផលរំពឹងទុក | ម៉ោង | |
|---|---|---|---|
| | | ទ្រ. ស | ទ្រ. សស |
| **ជំពូកទី១ : ប្រវត្តិសាស្ត្រកម្ពុជាក្នុងបរិបទតំបន់ និងពិភពលោក** | | | |
| **មេរៀនទី១ : សង្គមរាស្ត្រនិយម និងសង្គ្រាមត្រជាក់**<br>**សិក្សាបញ្ញត្តិ :** អព្យាក្រឹត សង្គ្រាមត្រជាក់ គំនាបបរទេស និន្នាការ ការបែកបាក់ ចលនាតស៊ូ អន្តរទំនាក់ទំនង<br>**មាតិកា :**<br>១.១- ឥទ្ធិពលសង្គ្រាមត្រជាក់ និងនយោបាយអព្យាក្រឹត<br>ក. ឥទ្ធិពលមហាអំណាច<br>ខ. បញ្ហាប្រឈមជាមួយថៃ<br>គ. បញ្ហាប្រឈមជាមួយវៀតណាម<br>• វៀតណាមខាងត្បូង<br>• វៀតណាមខាងជើង<br>សំណួរត្រិះរិះ :<br>• តើកម្ពុជាជួបការលំបាក និងកត្តាប្រឈមអ្វីខ្លះនៅពេលប្រកាន់យកនយោបាយ អព្យាក្រឹត? តើកម្ពុជាត្រូវដោះស្រាយការលំបាកនិងកត្តាប្រឈមនេះដោយរបៀបណា?<br>១.២- សង្គមរាស្ត្រនិយម និងប្រជាធិបតេយ្យ<br>ក. លទ្ធិប្រជាធិបតេយ្យបែបបស្ចិមប្រទេស | **វិជ្ជាសម្បទា**<br>- ប្រាប់ពីនយោបាយអព្យាក្រឹតក្នុងសម័យសង្គ្រាមត្រជាក់<br>- ពន្យល់ពីនិន្នាការប្រជាធិបតេយ្យនៅកម្ពុជា។<br>**បំណិនសម្បទា**<br>- វិភាគឥទ្ធិពលមហាអំណាចមកលើនយោបាយកម្ពុជា<br>- ពន្យល់ពីទំនាស់ផលប្រយោជន៍ក្នុងប្រទេសដែលបង្កឱ្យកម្ពុជាចុះខ្សោយ ឱនភាព និងបែកបាក់សាមគ្គី។<br>**ចរិយាសម្បទា**<br>- វិនិច្ឆ័យពីការអភិវឌ្ឍប្រទេសដោយប្រើមេរៀនប្រវត្តិសាស្ត្រ<br>- បង្កើតទម្លាប់នៃការគិត និងទង្វើវិជ្ជមានក្នុងការទទួលយកជំនឿ និងនិន្នាការនយោបាយខុសគ្នា។ | ៧ ម៉ | ១៤ ម៉ |

| | | | |
|---|---|---|---|
| ខ. ប្រជាធិបតេយ្យ និងសង្គមរាស្ត្រនិយម<br>សំណួរត្រិះរិះ :<br>• តើហេតុអ្វីបានជាកម្ពុជាមាននិន្នាការទៅប្រជាធិបតេយ្យក្នុងបរិបទសង្គ្រាមត្រជាក់?<br>• បើប្រៀបធៀបជាមួយប្រទេសក្នុងតំបន់ តើប្រជាធិបតេយ្យនៅកម្ពុជាស្ថិតក្នុងស្ថានភាពយ៉ាងដូចម្ដេច?<br>១.៣-និន្នាការ និងការបែកបាក់ជាតិ<br>ក. ចលនាខ្មែរសេរី<br>ខ. ចលនាខ្មែរកុម្មុយនីស្ត<br>គ. ចលនាបះបោររបស់កសិករ<br>• ករណីសំឡូត<br>• ករណីរតនគិរី<br>សំណួរត្រិះរិះ :<br>• តើឥទ្ធិពលនយោបាយរបស់មហាអំណាចបង្កវិបត្តិ និងផ្ដល់ប្រយោជន៍អ្វីខ្លះដល់ កម្ពុជា?<br>• តើកម្ពុជាចុះឱនភាព និងបែកបាក់សាមគ្គីជាតិ ដោយសារឥទ្ធិពលនយោបាយមហាអំណាច ឬ ទំនាស់ផលប្រយោជន៍ក្នុងប្រទេស?<br>១.៤-ទំនាក់ទំនងការបរទេស និងបម្រែបម្រួលសង្គម-សេដ្ឋកិច្ច<br>ក. កម្ពុជា និងអាមេរិក<br>ខ. កម្ពុជា និងចិន<br>គ. កម្ពុជា និងសូវៀត<br>ឃ. កម្ពុជា និងប្រទេសសង្គមនិយម<br>ង. កម្ពុជា និងប្រទេសក្នុងតំបន់<br>សំណួរត្រិះរិះ :<br>• តើទំនាក់ទំនងការបរទេសមានឥទ្ធិពលយ៉ាងដូចម្ដេចខ្លះចំពោះការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចកម្ពុជាក្នុងសម័យសង្គមរាស្ត្រនិយម?<br>១.៥- ចូរត្រិះរិះ<br>សំណួរត្រិះរិះ :<br>• តាមបទពិសោធប្រវត្តិសាស្ត្រ តើការអភិវឌ្ឍប្រទេស ត្រូវពឹងអាស្រ័យលើគោលការណ៍ | | | |

| | | | |
|---|---|---|---|
| ចម្បងៗអ្វីខ្លះ?<br>• តើយុវជនជំនាន់ក្រោយត្រូវប្រកាន់ឥរិយាបថបែបណាដើម្បីជៀសវាងការបែកបាក់សាមគ្គីជាតិដែលបង្កជាជម្លោះរវាងជាតិសាសនឯង?<br>• តើការឱ្យតម្លៃចំពោះជំនឿ និងទស្សនៈផ្សេងគ្នាផ្ដល់ប្រយោជន៍អ្វីខ្លះដល់ការអភិវឌ្ឍប្រទេស? | | | |
